ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

# ៦

ទស្សនាវដ្ដី ផ្សាយផែដំណឹងខាងសាសនា និងអក្សរសាស្ត្រ របោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ស្វា : ហ.ឃ.
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ | សេចក្ដីជូនដំណឹង អំពីការឲ្យរង្វាន់ដល់អ្នកប្រឡងជាប់ | ៤០១ |
| | សេចក្ដីជូនដំណឹងអំពីការប្រឡងទំនៀមទម្លាប់ខ្មែរ | ៤០៣ |
| — គ — | | |
| លោក ជាប់-សាក់ | រឿងចាប់ជ្រូកព្រៃ (រង្វាន់លេខ ១) | ៤០៩ |
| លោក ភិយ-ប៊ុក សមុហបញ្ជី | សុភាសិតបារាំងសែស (តមក) | ៤១៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន (តមក) | ៤១៩ |
| ឃុនសុន្ទរមេធី ញង-សៀង | ឯកសហស្សរាត្រីភាគទី ១៥ (តមក) | ៤២៧ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមទ្ធ) | ៤៤០ |

ផ្នែកសាសនា

| | | |
|---|---|---|
| លោកគ្រូព្រះសព្វញ្ញុះវិភទ្ទញាណ សោម-ឡុច ក្រុមជំនុំព្រះត្រៃបិដក | មធុរភាសិត (តមក) | ៤៤៧ |
| លោកគ្រូព្រះទេពមុនី ប៊ូរ-ប៊ុណ្ណ ក្រុមជំនុំព្រះត្រៃបិដក | បរិយាយ សាមគ្គី | ៤៥៤ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ពន្លឺអាស៊ីទ្វីប | ៤៦៨ |
| [illegible] | កតែងតាំងលោកៈតាំងកៅអធិការវត្ត | ៤៧៣ |

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Braḥ Déb satthā So-HAY membre de la Commission du Tripitaka


## *TABLE DES MATIÈRES*

### Partie littéraire :


| | | page |
|---|---|---|
| Commission des Mœurs et coutumes | Proclamation des résultats du concours littéraire organisé par la commission ..................... | 401 |
| —id— | Organisation du nouveau concours .. | 403 |
| Monsieur THACH SAK | La capture du Sanglier (1er prix)... | 409 |
| Monsieur RAY - BUC Chef Comptable (I. B.) | Proverbes français (suite) .......... | 413 |
| Luong Nibandhamantri NHOK-THÈM (I. B.) | Histoire de Chine (suite) ........... | 419 |
| Khun Sundaramedhi NHÔUNG - SŒUNG (I. B.) | "Mille et une nuits" facs 15 (suite). | 427 |
| Neak Oknha Vipularājasenā NOU-KAN Député | Histoire de Sam kok (suite) ...... | 440 |


### Partie religieuse:


| | | |
|---|---|---|
| Vén. SOM - LOCH ancien membre de la commission du Tripitaka | Madhuraphāsit (suite)............ | 447 |
| Vén. YOU-PONN membre de la commission du Tripitaka | Bâriyay Sāmaggi ............... | 454 |
| Luong Nibandhamantri NHOK-THÉM (I. B.) | Lumière de l'Asie (vie du Bouddha).. | 468 |
| Monsieur REAM-CHHOON Yokbat (Ministère des cultes) | Nomination de Chau Adhikar...... | 473 |

# សេចក្តីជូនដំណឹងអំពីការឲ្យរង្វាន់
# ដល់អ្នកប្រឡងទំនៀមទម្លាប់ខ្មែរ
# ដែលបានជាប់លេខ

---

កាលពីថ្ងៃ ២៩ ខែសេបតេម្ប្រ៍ ឆ្នាំ ១៩៤៧ ដល់ថ្ងៃ ៣១ ខែមារា ឆ្នាំ ១៩៤៨ រវាង ៦ ខែ ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ បានប្រកាសការប្រឡងទំនៀមទម្លាប់ ២ រឿងគឺ

១ — រឿងព្រេងទាក់ទងដោយការភ្ជួរស្រែ

២ — រឿងព្រេងទាក់ទងដោយការបាញ់-ទាក់សត្វ

ក្នុងរវាង ៦ ខែនេះ មានបេក្ខជន បានតែងរឿងផ្ញើទៅប្រឡងជាច្រើន ក្រុមជំនុំបានជួបជុំគ្នាពិនិត្យរឿងទាំងនោះ បានឲ្យរឿង ៦ ជាប់លេខ គឺបានជូនរង្វាន់ដល់បេក្ខជន ៦ នាក់ ដូចមាននាមរឿងនឹងនាមបេក្ខជនតទៅនេះ:

រង្វាន់ការបាញ់និងការទាក់សត្វ:

១ — រឿងទាក់ជ្រូកព្រៃ របស់លោក ថាច់-សាក់ អ្នកបង្ហាត់សិស្សនៅសាលារៀនគោកត្នូរ ផ្ទះលេខ ៩២ ផ្លូវប៊ូលបែរ ភ្នំពេញ ជាប់លេខ ១ បានរង្វាន់ ៥០ រៀល ។

២ — រឿងហ្វាបចាក របស់លោក មាស-ហាំ-ឬ ក្រឡាក់ស្រុក ស្រុកកំពង់ស្វាយ កំពង់ធំ ជាប់លេខ ២ បានរង្វាន់ ៣០ រៀល ។

៣ — រឿងការសំគមបាញ់លលក របស់លោក កិត្តិ ឈឹម - សាហេត គង់វត្តឧណ្ណាលោម ភ្នំពេញ ជាប់លេខ ៣ បានរង្វាន់ ១៥ រៀល ។

៣ — រឿងការទាក់ដីរ របស់លោក ទុ. ងិត ធ្វើការនៅស្ថានីយ៍ រថភ្លើង ស្ថានីយ៍ទទឹងថ្ងៃ ខេត្តពោធិ៍សាត់ ជាប់លេខ ៣ បានរង្វាន់ ១៥ រៀល ។

រង្វាន់ការច្រូតស្រូវ

៣ — រឿងរបៀបធ្វើស្រែ របស់លោក កិត្តិ រ័ត្ន-ជុតិ គង់វត្តឧណ្ណាលោម ភ្នំពេញ ជាប់លេខ ៣ បានរង្វាន់ ១៥ រៀល ។

៣ — រឿងការច្រូតស្រូវ របស់លោក សោម-សុខ ហៅ ចាន់-សុខ ស្មៀនឃុំ នៅឃុំកំពង់ត្រាច ស្រុកមាសហែក ខេត្តស្វាយរៀង ជាប់លេខ ៣ បានរង្វាន់ ១៥ រៀល ។

អ្នកតែងរឿងការបាញ់និងការទាក់សត្វ បានជាប់លេខ ៤ នាក់ គឺ ជាប់លេខ ១ មួយនាក់ លេខ ២ មួយនាក់ លេខ ៣ ពីរនាក់ ។ អ្នកតែងរឿងការច្រូតស្រូវ បានជាប់លេខតែ ២ នាក់ ហើយសុទ្ធតែលេខ ៣ ទាំងអស់ ដោយហេតុអ្នកតែងរឿងការច្រូតស្រូវ តែងខ្វះច្រើនអធ្វើ មិនសព្វគ្រប់តាមគោលដែលសួរ ។

ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ

នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

# សេចក្ដីជូនដំណឹង

## អំពីការប្រឡងទំនៀមទម្លាប់ខ្មែរ

នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបង្កើតក្រុម ១ ហៅថា "ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ" ក្រុមជំនុំនេះ ធ្វើការប្រមូលកត់ត្រាទុកនូវអក្សរធម៌-ទំនៀមទម្លាប់របស់ខ្មែរតាំងសម័យបុរាណ និងសម័យបច្ចុប្បន្ន ឲ្យដឹងថាខ្មែរសម័យបុរាណនិងសម័យបច្ចុប្បន្ន មានអក្សរធម៌ដូចម្ដេចខ្លះ ការទំនៀមទម្លាប់ដូចម្ដេចខ្លះ ៗ រួបរួមហើយរៀបរៀងបោះពុម្ពផ្សាយ ដើម្បីញ៉ាំងប្រជាជនជាតិខ្មែរឲ្យដឹងប្រវត្តិសាស្ត្រ និងអក្សរធម៌-ទំនៀមទម្លាប់នៃជាតិរបស់ខ្លួន និងដើម្បីញ៉ាំងនានាប្រទេសក្នុងលោកឲ្យដឹងថាខ្មែរតាំងសម័យបុរាណនិងសម័យបច្ចុប្បន្ន ជាជាតិមួយមានអក្សរធម៌-ទំនៀមទម្លាប់ទាំងផ្លូវលោកផ្លូវធម៌ល្អប្រពៃ តាំងពីសម័យអង្គរដែលជាសម័យមាសរបស់ខ្មែរ រហូតមកដល់សព្វថ្ងៃនេះ ៗ

កិច្ចការរបស់ក្រុមជំនុំនេះ នឹងបានជាគោលការណ៍ដ៏ធំមហិមាក្នុងការសិក្សាប្រវត្តិសាស្ត្រនិងអក្សរធម៌-ទំនៀមទម្លាប់ខ្មែរ ជាកិច្ចការរក្សាប្រទេសជាតិ សាសនារបស់ខ្មែរឲ្យគង់វង្សនៅបាន នឹងបានចំរើនតទៅខាងមុខ ៗ

ឥឡូវ ក្រុមជំនុំនេះ ត្រូវការប្រមូលរឿង ២ គឺ:

១ - រឿងរបររកស៊ីផ្សេងៗ

២ - រឿងល្បែងផ្សេងៗ

ទើបជូនដំណឹងដល់អស់លោកអ្នកចេះដឹងទូទៅ ទាំងកម្ពុជរដ្ឋទាំងមូល សូមឲ្យសរសេរតែងរឿងទាំងនេះ ផ្ញើទៅប្រឡងឯមន្ទីរពុទ្ធ-សាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។ កាលអស់លោកអ្នកតែងផ្ញើទៅដល់ហើយ ក្រុមជំនុំនឹងប្រជុំគ្នាពិនិត្យមើល បើឃើញថាសេចក្ដីតែងរបស់លោក-អ្នកណា ល្អជាងគេ នឹងឲ្យលេខហើយនឹងជូនរង្វាន់ ។ ឯលេខនឹងរង្វាន់នោះចែកជា ៣ ថ្នាក់ គឺថ្នាក់លេខ ១ ជូន ៦០ រៀល លេខ ២ ជូន ៤៥ រៀល លេខ ៣ ជូន ៣០ រៀល ។ រង្វាន់នោះបើលោកអ្នកប្រឡងជាប់លេខណា ចង់យកជាប្រាក់ក៏បាន ជាសៀវភៅបោះពុម្ពរបស់ពុទ្ធសាសនបណ្ឌិត្យក៏បាន ។ ដើម្បីឲ្យការនេះបានស្រួលហើយឆាប់ សូមលោកអ្នកប្រឡងគ្រប់គ្នា សរសេរសេចក្ដីបញ្ជាក់បន្តិចនៅខាងចុងរឿងដែលផ្ញើទៅប្រឡងនោះៗ តាំងពីដំបូងថា "ត្រូវការជាប្រាក់ ឬសៀវភៅ" បង្ហាញទុកឲ្យហើយ ក្រែងលោបានជាប់ ។

ក្នុងលោកអ្នកប្រឡងម្នាក់ៗ ចង់តែងទាំង ២ រឿង គឺទាំងរឿងរបរ ទាំងរឿងល្បែងក៏បាន តែ ១ រឿងក៏បាន ។ បើចង់តែងទាំង ២ រឿង ត្រូវសរសេររឿងនីមួយៗ លើក្រដាសដាច់ដោយឡែកពីគ្នា បើលោកអ្នកប្រឡងណាម្នាក់តែងបាន ២ រឿង ហើយជារឿងល្អជាងគេទាំង ២ នោះគាប់បានជាប់លេខទាំង ២ រឿង បានរង្វាន់ជា ២ ផ្នែក គួរនាជួប

លោកអ្នកណាម្នាក់តែងរឿងរបររកស៊ីបានជាប់លេខ ១ រឿងល្បែងក៏ជាប់លេខ ១ ដូចគ្នា នោះគឺនឹងត្រូវបានរង្វាន់ថ្នាក់លេខ ១ ពីរដង បើប្រសិនជារឿងរបររកស៊ីជាប់លេខ ១ រឿងល្បែងជាប់លេខ ២ ឬ ៣ នោះនឹងត្រូវបានរង្វាន់ថ្នាក់លេខ ១ មួង លេខ ២ ឬ ៣ មួង ដូច្នេះជាដើម ។

ឯការរៀបរៀងសេចក្តី កុំបាច់គិតពីរបៀបពាក្យពេចន៍ អក្សរខុសត្រូវអាក្រក់ល្អឡើយ គិតតែពីរៀបចប់ឲ្យសព្វគ្រប់កិច្ចការកងរបររកស៊ី ឬល្បែងនោះ ៗ ប៉ុណ្ណោះ ។ បើអ្នកប្រឡងចង់សរសេរជាអក្សរបារាំងក៏បាន តែត្រូវសរសេរឈ្មោះរបរ - ល្បែង - មនុស្ស - ប្រដាប់ធ្វើរបរ ឬល្បែងនោះ ៗ នឹងពាក្យប្លែក ៗ ខ្លះជាអក្សរខ្មែរ ។

រឿងដែលប្រឡងទាំងអម្បាលម៉ាន ត្រូវឲ្យបានទៅដល់ក្រុមជំនុំទំនៀមទម្លាប់នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ មុនថ្ងៃ ៣១ ខែធ្នូ (ដេសម្ប្រ៍) ឆ្នាំ ១៩៤៨, គឺ ថ្ងៃ សុក្រ ១ កើតខែបុស្ស ព. ស. ២៤៩១ ។

រឿងដែលប្រឡងនោះ បើតែងរួចហើយត្រូវយកទៅជូនមេឃុំឬចៅហ្វាយស្រុក - ខេត្ត ដែលនៅជិតនោះ ឲ្យផ្ញើទៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ តាមផ្លូវពេជការក៏បាន លោកអ្នកប្រឡងយកទៅឲ្យពុទ្ធសាសនបណ្ឌិត្យផ្ទាល់ខ្លួនក៏បាន ។

# សេចក្ដីពន្យល់អំពីគោលនៃការតែងរឿងប្រឡង

## ១- រឿងរបររកស៊ី ២ រឿងល្បែង

ក) សូមតែងចំពោះតែរឿងរបរ ឬល្បែងជនជាតិខ្មែរ ដូចរបរស្រែ-ពោត-ថ្នាំ-តំបាញ-ជាងមាស-នេសាទត្រី ជាដើម ក្រៅពីនេះតាមតែរបរណាក៏ត្រូវការទាំងអស់ (វៀរលែងតែការកេងការ) ។ល។ ដូចល្បែងឈូង-លោតអន្ទាក់-លាក់កន្សែង-ចាប់កូនខ្លែង-ហ៊ឹង-កូនគោល-បាយខុំជាដើម ក្រៅពីនេះតាមតែល្បែងណាក៏ត្រូវការទាំងអស់ (វៀរលែងតែ បៀ-ជួ) ។

ខ) លោកអ្នកប្រឡងចង់តែងត្រង់មុខរបរ ត្រង់មុខល្បែង ឬគិតមុខក៏បាន ។ កាលបើតែងអំពីរបរឬល្បែងណា ត្រូវប្រាប់ឲ្យជាក់ថារបរឬល្បែងនោះមាននៅស្រុកនោះ លោកអ្នកតែងធ្លាប់ធ្វើធ្លាប់លេងផ្ទាល់ខ្លួន ឬគ្រាន់តែឃើញគេធ្វើគេលេងឬក៏ដឹងតាមអក្សរណា ជារបស់ខ្លួនឬរបស់អ្នកណា នៅទីណា ។

គ) លោកអ្នកប្រឡងត្រូវការតែងរឿងរបរឬល្បែងណា ។ សូមរៀបរាប់អំពីគ្រឿងប្រដាប់របរឬល្បែងនោះៗឲ្យសព្វគ្រប់ដូចរបរស្រែត្រូវរៀបរាប់អំពីនង្គ័ល-នាស់-ជាដើម ។ល។ របរនេសាទត្រីត្រូវរៀបរាប់អំពីសំណាញ់-អួន-មង-អញ្ចូង ជាដើម ។ល។ របរតំបាញត្រូវ

រៀបរាប់អំពីហាត់នឹងកីជាដើម ។ល។ ល្បែងឈូងគេយកអ្វីមកធ្វើឈូងជាដើម ។ល។ បាយខុំគេយកអ្វីមកលេងជាដើម ។ល។ គ្រឿងប្រដាប់អស់នោះ មានទ្រង់ទ្រាយដូចម្ដេចខ្លះ ព្រមទាំងរៀបរាប់អំពីកិច្ចការក្នុងរបរល្បែងនោះៗផង តាំងពីពេលផ្ដើមធ្វើផ្ដើមលេង រហូតដល់ធ្វើដល់លេងរួចស្រេច ។

ឃ) របរល្បែងណា មានមនុស្សអ្នកធ្វើ ឬអ្នកលេងប៉ុន្មាននាក់ របរល្បែងណាគេតែងធ្វើឬលេង រដូវណាខែណា ឬមិនកំណត់រដូវ គេលេងក្នុងបុណ្យ ឬមង្គលអ្វី លេងថ្ងៃឬយប់ ឬទាំងថ្ងៃទាំងយប់ សូមបរិយាយឲ្យសព្វគ្រប់ ។

ង) នៅស្រុកណា មានរបរល្បែងអ្វីខ្លះ ដែលប្លែកឬដំជាងស្រុកឯទៀតៗ ។

ច) បើប្រសិនជាលោកអ្នកប្រឡង អាចដឹងរឿងព្រេងទាក់ទងដោយរបរល្បែងណា សូមសរសេរតែងរឿងនោះដាក់ទៅផង តែសូមប្រាប់ដើមកំណើតរឿងនោះថា បានដឹងពីអ្នកណា នៅទីណា គេដំណាលប្រាប់ ពីសាស្ត្រាណាឬសៀវភៅណារបស់អ្នកណា នៅទីណា បើសៀវភៅបោះពុម្ព ឬសាស្ត្រាស្លឹករឹត ត្រូវប្រាប់ឈ្មោះ ប្រាប់ទំព័រ ប្រាប់អង្កា បើមិនដឹងរឿងព្រេងទេ សូមតែងតែរឿងរបរល្បែងចុះ ។

ង) បើបវេរ្នល្បែងណា មានក្រណម ឬពិធីដូចម្ដេច ល្បែងណា ទាក់ទងដោយសាសនាណា ក៏សូមបរិយាយផង ។

ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ
នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ
ក្រុងភ្នំពេញ

# រឿងទាក់ជ្រូកព្រៃ

## សូមជូនមកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

---

ដើម្បីនឹងសូមប្រឡងអំពីរឿងប្រដេញជ្រូកព្រៃតាមរបៀបបុរាណ រឿងនេះ ខ្ញុំបាទបានឮឈ្មោះ គឹម-សេក អាយុ ១៩ ឆ្នាំ ធ្វើការនៅសាលារៀនគេអាគន្ទូរ៍ លេខ ៩២ ផ្លូវប៉ូលបែរ ភ្នំពេញ បាននិយាយរឿងនេះប្រាប់ខ្ញុំបាទនៅថ្ងៃទី ២៦ មករា គ.ស. ១៩៤៨ វេលាម៉ោង ១១ និង ៣០នាទី រឿងនោះដូចតទៅនេះ:

តាមរបៀបអ្នកស្រុក នៅស្រុកទិនបៀង ឃុំធៀកណាប ភូមិព្រៃទទឹង ខេត្តបូរជុក (មាត់ជ្រូក) គេតែងតែទៅទាក់ជ្រូកព្រៃនៅដើមក្ដៅពាល ក្នុងស្រុកខាងលើនេះ ប៉ុន្តែគេទៅដេញតាមរដូវ គឺរដូវរំហើយ ខែអស្សុជ កត្តិក ផល្គុន ហើយនឹងចេត្រ អ្នកស្រុកដែលនៅស្រុកនោះ តែងតែដល់រដូវទៅដេញសត្វហើយ អ្នកដែលគេតែងទៅប្រដេញនោះ គេប្រើប្រាស់គ្រឿងប្រដាប់សម្រាប់ទៅទាក់ ប្រដាប់នោះគេហៅថាបង្កាត់ ឯបង្កាត់នោះមានសណ្ឋានដូចជាមងដែលសម្រាប់ដាក់ត្រី ប៉ុន្តែក្រឡាធំៗ ជាងក្រឡាមងធម្មតា ហើយក្រឡានោះធ្វើអំពីខ្សែដក់ដូនគូបៗ ដូចជាខ្សែដែលគេដេរក្ដោងទូក ហើយមានមេពីរទំហំប៉ុនមេដៃ បង្កាត់នោះមានប្រវែង ១០ ឬ ១២ ម, បណ្ដោយ ឯទទឹងប្រហែលជា ៣ ឬ ៤ ម, ៗ

របៀបយកបង្កាត់នោះ គឺ គេយកមេបង្កាត់ដាក់ខាងលើបង្គោលតូចប៉ុនកដៃក្មេង ឯបង្គោលនោះគេដោតបន្ទុំស្មើៗ លើដី អាចនឹងរលំមកខាងមុខបានដោយងាយ កាលណាតែមានសត្វអ្វីបោលទៅប៉ះបង្កាត់នោះ, មេបង្កាត់ខាងក្រោមគេដាក់ឲ្យប៉ះនឹងដី ហើយត្រណមបង្កាត់នោះ គឺគេហាមមិនឲ្យអ្នកឯណាដើរកន្លងលើឡើយ ។

លុះដល់ថ្ងៃដេញទៅដេញសត្វនោះ មេប្រមូលគ្នាអ្នកដែលនៅជិតខាងនោះចំនួនជា ៥០ ឬ ៦០ នាក់ អ្នកឯណាចង់ទៅក៏ទៅបានដែរ មិនចំពោះតែអ្នកមានបង្កាត់ទេដែលទៅបាននោះ អ្នកដែលគ្មានបង្កាត់ក៏ទៅបានដែរ គេទៅម្តងៗ មានបង្កាត់ចំនួនជា ៥ ឬ ៦ ។

មុននឹងចេញទៅនោះ គេប្រុងប្រៀបគ្រឿងសក្ការបូជា គឺ បាយសីប្រាំថ្នាក់ ១ គូ ស្លាធម៌ដៃ ១ គូ ទៀន ៥ ធូប ៥ មាន់ស្ងោរ ១ សំរាប់យកទៅថ្វាយបង់បត់ដែលនៅប្រកឡើងទៅក្នុងពាល លុះបានគ្រប់ប្រដាប់ប្រដាហើយ ក៏នាំគ្នាចេញទៅ អ្នកដែលទៅតាំងអំបាលម៉ាន សុទ្ធសឹងមានអាវុធសំរាប់ការពារអាត្មា អ្នកខ្លះមានកាំបិតស្នៀត អ្នកខ្លះដាវលំពែង អ្នកខ្លះស្នា អ្នកខ្លះទៀតកាំបិតផ្គាក់តូចៅ ។

លុះនាំគ្នាទៅដល់ដើមពោធិ៍នៅប្រកឡើងទៅក្នុងពាល ក៏យកគ្រឿងសក្ការៈទាំងនោះទៅបូជា បង់បត់ដែលនៅប្រកក្នុងក្រោមដើមពោធិ៍នោះ បង់បត់នោះខាងគាត់ឈ្មោះហៅយគង់ កាលដើមឡើយ កំណើត

យាយគង់នេះ នៅស្រុកឃួនក្លូសាំងស៊ុនឯនោះទេ ប៉ុន្តែដោយសារ មានជាតិប៉ាក់ងម្នាក់ បាននៅព្យាបាលទីលំនៅរបស់គាត់នោះ គាត់ក៏ត្រឡប់មកនៅៗ ដើងក្នុពពាលនេះ បានជាគេដឹងថាគាត់មកនៅៗ ដើងក្នុពពាលនេះ ពីព្រោះកាលដែលមកដល់ស្រុកនោះភ្លាមក៏ទៅចូលនឹងរូបស្រីម្នាក់ចាស់មានទាមពុំប្រាកដ ចូលមកភ្លាមនិយាយរឿងការប្រាប់គេឯងកលក្នា ។

លុះគេដឹងថាគាត់មកនៅៗ ទីនោះ គេក៏បបួលគ្នាទៅសង់អាស្រមឲ្យគាត់នៅក្រោមដើមពោធិ៍ដែលនៅប៉ែកក្នុពពាលនោះ អ្នកណាដែលត្រូវការឡើងទៅលើភ្នំនោះ ត្រូវតែយកគ្រឿងសក្ការៈផ្សេងៗទៅថ្វាយ បើពុំនោះទេមុខជាប្រទះនឹងគ្រោះថ្នាក់មិនខាន គឺជួបប្រទះនឹងសត្វសា-ហាវមិនខានទេ ។

លុះអ្នកដែលទៅទាក់ជ្រកព្រៃនោះ រៀបថ្វាយរួចស្រេចហើយក៏នាំគ្នាដើរឡើងទៅលើភ្នំ ។

លុះកាលដែលអ្នកអស់នោះដើរទៅឆ្ងាយពីអាស្រមនោះក៏បែកគ្នាជាពីរពួក មួយពួកឲ្យនៅចាំដើមផ្លូវ មួយពួកទៀតឲ្យដើរយកបង្កាត់ទៅកប់ចម្ងាយពីដើមផ្លូវទៅប្រហែលជាមួយគីឡូឬពីរគីឡូម៉ែត្រ បង្កាត់នោះគេកប់ឃ្លាតពីគ្នាពីមួយទៅមួយទុកចន្លោះកណ្ដាលប្រហែលជាប្រាំឬប្រាំមួយម៉ែត្រ នៅតាមចន្លោះបង្កាត់នោះគេឲ្យមនុស្សយាមពីរឬបីនាក់ ។

លុះកាយបង្កាត់រួចស្រេចហើយ ក៏ចាត់គ្នាឲ្យមកប្រាប់អ្នកដែលនៅចាំដើមផ្លូវបានដឹង លុះបានដឹងហើយក៏កាយគ្នាចម្ងាយពីមួយទៅជង្ហ គ្នា នាំគ្នាស្រែកហោកញ្ជ្រៀវ កាយព្រៃផ្សេងៗ ជ្រូកដែលលាក់ខ្លួនក្នុងព្រៃនោះផ្អើល រត់ចូលទៅក្នុងបង្កាត់ដែលកាយនៅខាងមុខ ។

លុះដេញទៅដល់ជិតបង្កាត់នោះកាលណា ក៏នាំគ្នាស្រែកតែតែខ្លាំងឡើង ៗ ម្ល៉ោះហើយសត្វដែលរត់ទៅនោះលុះដោយអំណាចសន្ធាប់របស់គេ ក៏ចេះតែរត់តែខ្លាំងឡើងដើម្បីឲ្យរួចខ្លួន លុះបោលរត់ទៅស្រាប់តែចូលទៅក្នុងបង្កាត់នោះៗ ក៏មូររុំជាប់ជុំវិញខ្លួនរកតែទៅខាងណាក៏ពុំរួច ៗ ចំណែកអ្នកដែលនៅយាមបង្កាត់នោះ កាលបើឃើញជ្រូកជាប់ដូច្នោះហើយ ក៏រត់ទៅចាក់កាប់សម្លាប់ឥតត្រាប្រណីដល់តិចឡើយ ។

ចំណែកអ្នកដែលជាម្ចាស់បង្កាត់ត្រូវបានក្បាលជើងហើយនឹងកន្ទុយ ចំណែកអ្នកដែលមិនមែនម្ចាស់បង្កាត់ត្រូវបានសាច់ តាមចំនួនសត្វដែលចាក់បាន ទៅចាក់ម្តងៗ ជួនកាលបាន ៣ ឬ ៤ ។

បានជាអ្នកស្រុកគេតែងទៅប្រដេញនៅរដូវហើយ ដូចពោលមកខាងដើមនោះ ពីព្រោះនៅរដូវនោះស្រូវទុំ ជ្រូកតែងចុះមកបរិភោគស្រូវស្រែដែលនៅជិតជើងភ្នំពេលនោះ ។

ចាប់-សាក់ អ្នកបង្ហាត់សិស្ស នៅសាលារៀនគេអាពន្ធ្វី

# សុភាសិតបារាំងសែស

## លោក ពាយ-ប៊ុក ប្រែ លោក ញ៉ុក-ថែម ពិនិត្យកែ

(តមក)

---

31°— Le travail est un trésor.

៣១ .— ការងារជាឃ្លាំងប្រាក់ .

"ធ្វើការបានប្រាក់ ធ្វើការបានសក្តិ ធ្វើការបានយស ធ្វើការបានទ្រព្យ បានវិជ្ជាស្មោះ ចំរើនឥតថ្លស់ ដោយសារការងារ" ។

32 .— Il faut battre le fer quand il est chaud .

៣២ .— ត្រូវដំដែក ក្នុងពេលដែលកំពុងក្តៅ ។

"ធ្វើស្រែទាន់មានភ្លៀង ទំស្រែកក្បៀងទាន់ចិត្តបង់ សាងជាតិដោយស្មោះត្រង់ ទំបង់ស្រែទាន់ក្តៅចិត្ត" ។

33.— Ce qui vient de la flûte s'en va par le tambour.

៣៣ .— របស់ដែលបានមកជាប៉ី ផលចេញទៅវិញជាស្គរ ។

"ទ្រព្យដែលគេបាន ដោយទូរលំអាន មិនសូវព្យល្បី ផលខ្ចាត់ បាត់ទៅ តាកលំនៅខ្ទី ព្យស័ព្ទស្រដី ល្បីពេញទាំងស្រុក" ។

34°— Les absents sont toujours torts.

៣៤ .— អ្នកមិននៅបេះតែខុស ។

អ្នកមានទោសច្រើនអាងអ្នកស្លាប់ទៅ ត្រង់ខុសត្រូវរៀងខ្ទូនមើលមិនយល់ បុកណាបណ្ឌិតពិនិត្យគិតតាមយោបល់ កុសលអកុសលត្រូវពិចារណា" ។

35°— On est toujours heureux le soir quand on a bien rempli la journée.

៣៥.- កាលបើគេបានបំពេញអំពើល្អ ក្នុងវេលាថ្ងៃ ដល់ពេលល្ងាច គេនឹងបានសប្បាយចិត្តជានិច្ច ។

"ពេលថ្ងៃធ្វើល្អ ប្រព្រឹត្តធម៌ស សុចរិតជានិច្ច ដល់ទៅពេលល្ងាច គិតឃើញតែកិច្ច ការល្អច្រើនតិច សប្បាយចិត្តគាប់" ។

36° — A force de forger, on devient forgeron.

៣៦.— ជនខំដំដែក គេនឹងទៅជាជាងដំដែក-

"ខំរៀនទើបចេះ ខំផ្លុំទើបឆេះ ខំធ្វើបានផល ឥតអំពល់ទុក្ខ ខំដើរទើបដល់ ខំគិតទើបយល់ ព្រោះផលព្យាយាម" ។

37. — Il faut manger pour vivre et non vivre pour manger.

៣៧.- ត្រូវស៊ីឲ្យគ្រាន់តែរស់ មិនមែនរស់គ្រាន់តែស៊ី ។

"ត្រូវដឹងប្រមាណ អាហារដែលបាន បរិភោគរាល់ថ្ងៃ ទោះមានតិចច្រើន ពេញចិត្តសំចៃ គប់គ្រាន់សព្វថ្ងៃ ទើបបានសុខសាន្ត" ។

38.-- Aide-toi le ciel t'aidera.

៣៨.- ចូរអ្នកជួយខ្លួនអ្នក ទើបទេវតាជួយអ្នក ។

"ខ្លួនទីពឹងខ្លួន បើខំខ្វល់តាមក្បួន លោកសំដែងទុក ត្រូវជួយខ្លួនឯង ទើបបានក្តីសុខ អ្នកផងយល់មុខ ទុកចិត្តជួយថែម" ។

36. — Chercher une aiguille dans une boîte de foin.

៣៩.- រកម្ជុលមួយជ្រុងក្នុងគំនរចំបើង ។

"ការធ្វើហួសវិស័យ ជាបច្ច័យវិនាសប្រាណ ព្យាយាមអម្បាលម៉ាន មិនសម្រេចប្រយោជន៍ឡើយ ។

40.— Faire l'âne pour avoir du son.

៤០. ធ្វើលាប៉ិនយកកន្ទក់ ។

"ធ្វើធ្មេតដើម្បីស្តាប់កិច្ចការ ធ្វើកម៉ដើម្បីក្រេបរសជាតិ ព្យាយាម មុតមាំកុំបីឃ្លាត ប្រឹងស្វែងតសូផ្គត់គន់ឃើញផល" ។

41. — Bouche d'un démon, cœur d'un ange.

៤១.- មាត់ជាយក្ស ចិត្តជាទេព្ដា ។

"មាត់អាក្រក់ចិត្តប្រិនសោភ័ណ ចិត្តថ្លើមសាន់រ៉ន់ប្រិនមាត់ល្អ ឯបែបភាពមារយាទខ្ពស់ កម្រយល់ពិតបណ្ឌិតដឹង" ។

42.— Entre l'arbre et l'écorce, il ne faut pas mettre le doigt.

៤២.- កុំដាក់ម្រាមដៃ ក្នុងចន្លោះដើមនឹងសំបក ។

"ការឈ្លោះគាស់គ្នា ញាតិផៅមិត្រគ្នា យើងអ្នកដទៃ មិនត្រូវ ជ្រៀតជ្រែក ដដែកបំភ័យ ឲ្យម្ខាងមានជ័យ កើតគាស់គ្នាខ្លាំង" ។

43. — Couper l'arbre pour avoir le fruit.

៤៣.- កាប់ដើមយកផ្លែ ។

"សម្លាប់មេមាន់យកពងមាស ចិត្តលោភពេញពាសជាសត្វសុជា ខ្លួនរៀតូចតាបភាពដូចតា ប្រាថ្នាផ្លែលហួសនឹងហ៊ានប្រាណ" ។

44. — Tout est vide et vanité sur ce monde.

៤៤.— របស់ទាំងអស់ជារបស់សោះសូន្យ នឹងជារបស់លល្បួន បញ្ឆោតនៅក្នុងលោកនេះ ។

"លោកនេះសោះសូន្យ កើតស្លាប់ពពូន ច្រើនជាអនេក កើតស្លាប់មុនចាស់ ឃើញច្បាស់នឹងភ្នែក គ្រប់ជាន់គ្រប់ផ្នែក សាបសូន្យអសារ" ។

45 .— On aperçoit la paille dans l'œil de son voisin et non la poutre qui est le sien.

៤៥ .— គេមើលឃើញតែសម្រាមនៅនឹងភ្នែកអ្នកដទៃ តែគេមើលមិនឃើញធ្នឹមបាក់នៅនឹងភ្នែករបស់ខ្លួន ។

"ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ មើលយល់ប៉ុនទាំងភ្នំ" ។

46 .— Fais bien et laisse le dire.

៤៦ .— ចូរធ្វើតែល្អទៅចុះ ហើយបើកឲ្យគេថាទៅចុះ ។

"ប្រព្រឹត្តសុចរិត កុសលក្រមក្រិត្យ ឧត្តមថ្លៃថ្លា អ្នកដទៃពោលតាមចិត្តគេថា ធ្វើល្អទេវតា ឲ្យពរជោគជ័យ" ។

47 .— Pour chercher un ami, il faut goûter beaucoup de sel avec lui.

៤៧ .— ស្វែងរកមិត្តសម្លាញ់ណាមួយ ត្រូវភ្លក់អំបិលជាមួយគ្នាជាច្រើនដង ។

"កល្យាណមិត្ត ស្មោះស្ម័គ្រនិត រកបានកម្រ លុះតែសេពគប់ ទើបយល់ខ្មៅស សុចរិតអាក្រក់ល្អ ដោយចេះពិចារណ៍" ។

48 — On vient à bout à qui sait attendre.

៤៨.— អ្នកដែលរង់ចាំគេទើបបានសម្រេចដូចបំណង ។

"ខន្តីអត់ធន់ បារមីនគុណធ្ងន់ សម្រេចប្រាថ្នា ចង់បានមានចិត្ត តាមគំនិតចិន្តា មិនបានផលា ត្រូវការប៉ុនប៉ង" ។

49 — Nul n'est content de son sort.

៤៩ — គ្មានអ្នកណាមួយពេញចិត្តនឹងជោគវាសនារបស់ខ្លួន ។

"ទិស្សយមនុស្សលោក មានច្រើនគរគោក កងភពសង្សារ មិន ថាមានក្រ គាប់ចិត្តវាសនា អាក្រក់ល្អយ៉ាងណា ពុំសូវមានឡើយ" ។

50 — Qui désire tout n'a rien.

៥០ - អ្នកដែលប្រាថ្នាតាំងអស់ មិនបានអ្វីសោះ ។

"មនុស្សលោកលង់ មិនឆ្អែតមិនឆ្អន់ បានច្រើនយ៉ាងណា នៅ តែខាតខ្វះ កន្ទះចិន្តា បរិវលោកា វែងបាត់ធន់ទៅ" ។

51 — Qui borne ses désirs est toujours assez riche

៥១ · អ្នកណាសន្តោស អ្នកនោះមានសម្បត្តិ គ្រប់គ្រាន់ជានិច្ច

"តណ្ហាជាមេខ្វះ បេះតែកន្ទះ មិនដែលគ្រប់គ្រាន់ អ្នកមាន សន្តោស ចិត្តលុះជាក់ស្បាន់ ក្រដេញមិនទាន់ ជាន់តែងកល់ថ្ងៃ" ។

52 — Deux avis valent mieux qu'un.

៥២ · សេចក្តីយល់ពីរជងមានដំឡៃជាងសេចក្តីយល់ឃើញមួយ

"គិតរួបសមធ្វើ បណ្ឌិតសរសើរ មិនសូវមានក្លាក់ បើយោបល់ ពីរ កាន់តែទៀងទាត់ មូលគ្នាពីរមាត់ ប្រាកដជាក់ស្បាន់" ។

53— Autant de têtes autant d'avis.

៥៣ - ក្បាលក៏ច្រើន មតិក៏ច្រើន ។

“មនុស្សមានច្រើនបែប គំនិតក៏ច្រើនបែប ខុសៗគ្នា លទ្ធិជាយ៉ាងខ្លួន មតិប្រាជ្ញ ប្រែល្អិតជួរខារ តាមតែយល់ចុះ” ។

54— Tout effet à une cause.

៥៤— ផលទាំងអស់កើតមកពីហេតុ ។

“មានភ្លើងមានផ្សែង មានល្អិតក្លិនផង ស៊ីកឈើក៏កើត ដ្បិតមាន ខ្យល់បក់ មច្ឆជាតិកើត ហែបហែលកន្ទុក ល្អក់ទឹកពុំជា” ។

55 — Quand le lit est bien préparé il faut qu'on sé couche.

៥៥ — កាលណាគ្រែដេកមករៀបចំបានស្រួលហើយគេត្រូវតែដេក ។

“ធ្វើការមិនប្រមាទ ខំសង្វាតឲ្យបានផល សង្គ្រាមក្នុងសាកល ប្រាជ្ញាផលគឺកំរៃ”

56 — Qui va lentement va loin.

៥៦ — អ្នកដែលដើរទៅសន្សឹម ៗ ទៅបានឆ្ងាយ ។

“អ្នកដែលដើរទៅមួយ ៗ ឥតទុក្ខព្រួយខ្វាចក្ដាត់ចំណាប់ ធ្វើការងារតាមសណ្ដាប់ មិនប្រញាប់ក្រែងក្ដាត់ស្បៀក” ។

57 — A beau mentir qui vient de loin.

៥៧ — អ្នកដែលមកពីឆ្ងាយ កុហកបានតាមចិត្ត ។

(មានត)

# ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន

## ហ្លួងនិពន្ធមន្ត្រី ញ៉ក-ថែម ប្រែរៀបរៀង

(តមក)

---

### វគ្គទី ៧

### រាជវង្សស៊ុង

## អំពីការចលាចលមុនតាំងរាជវង្សស៊ុង

ប្រសិនបើលោក-អ្នកបានអានពង្សាវតារចិន តាំងពីដើមរហូតមកដល់ត្រឹមណេះ នឹងឃើញច្បាស់ថា សេចក្តីប្រៀបខាងដើមថា ចិនទុកជាក្រុងរោមរបស់ទ្វីបអាស៊ីនោះ ជាសេចក្តីប្រៀបធៀបដ៏សមរម្យបំផុត ។ ហេតុភេទផ្សេងៗ ដែលមានក្នុងប្រវត្តិសាស្ត្រចិនក្តី ហេតុនៃសេចក្តីចំរើន និងសេចក្តីសាបសូន្យរបស់ក្សត្រចិន តាមដែលពោលមកហើយក្តី សឹងមានលក្ខណៈត្រូវគ្នានឹងក្រុងរោមជាច្រើន ។ ហេតុភេទរបស់ក្រុងរោមតមកខាងចុង មានសម័យដែលកើតចលាចលវឹកវរឡើងដោយសារទាហាន ដូចមានក្នុងពង្សាវតាររោមថា សម័យគ្រានោះជាសម័យដែលពួកទាហានបង្កសេចក្តីវិនាសសាបសូន្យ សម័យបែបនេះ ក៏មានក្នុងប្រវត្តិសាស្ត្ររបស់ចិនដែរ គឺគ្រាដែល ជូ-វេន បានផ្តួលរំលំព្រះមហាក្សត្ររាជវង្សថាំង អង្គក្រោយបង្អស់ កាលពីពុទ្ធសករាជ ១៤៥០ ហើយ

តាំងខ្លួនឯងឡើងជាព្រះរាជាធិរាជក្រុងចិន តាំងទីក្រុងនៅស្រុកខៃ-ហ្វុង ឯពួកមេទ័ពឯទៀតៗ ដែលមានកំឡាំងទាហានក៏នាំគ្នាយកតម្រាប់តាម ទើបប្រកាសខ្លួនជាឥស្សរៈដោយឡែកៗឡើង នៅខេត្តដែនដែលខ្លួនតាំងកងទាហាននោះ ។ បណ្ដាពួកដែលតាំងខ្លួនជាឥស្សរៈឡើងនោះ មានម្នាក់ដែលខ្លាំងពូកែហើយជាសត្រូវដ៏សំខាន់បំផុតនឹង ជូ-វេន ឈ្មោះ លី-កេយ៉ុង ជាជាតិតួកគីតាំងខ្លួនជាក្សត្រគ្រងរាជសម្បត្តិនៅខេត្តចាន់-ស៊ី ។ ក្នុងឆ្នាំពុទ្ធសករាជ ១៤៦៧ ព្រះរាជបុត្រប្រុសរបស់ក្សត្រថ្មីនេះ ឈ្មោះ លី-ជុនហ៊ុយ វាយយកស្រុកខៃ-ហ្វុងបាន ដណ្ដើមយករាជបល្ល័ង្កចិន ពីព្រះរាជាធិរាជជូ-វេនមកបាន ហើយតាំងរាជវង្សថ្មីឡើង ហៅថា ហៅ-ថាំង តាំងស្រុកលោ-យ៉ុង ជាទីក្រុង គ្រងរាជ្យបាន ១៣ ឆ្នាំ ទើបមានជាតិតួកគីម្នាក់ទៀតឈ្មោះ ថេ-តិងថាំង មកវាយយកស្រុកលោ-យ៉ុងបានទៀត ហើយតាំងរាជវង្សឡើងថ្មីទៀត ហៅថា វង្សហៅ-ជិន តាំងទីក្រុងនៅស្រុកខៃ-ហ្វុង ។ វង្សហៅ-ជិន គ្រងរាជ្យបានត្រឹម ១០ ឆ្នាំ ក៏ត្រូវពួកគី-តៃ មកវាយដណ្ដើមយករាជ-បល្ល័ង្កទៅទៀត តមកទៀត ១១ ឆ្នាំ ទើបមាននាយកជាតិតួកគីមួយថ្មី ហៅថាលៀវ-ជី មកវាយយកស្រុកខៃ-ហ្វុងទៅបាន ហើយតាំងរាជវង្សក្សត្រថ្មីឡើង ហៅថា វង្សហៅ-ហាន គ្រប់គ្រងរាជសម្បត្តិបានតែត្រឹម ៤ ឆ្នាំ ក៏មានតួកគីមួយពួកទៀតមកវាយបែកដណ្ដើមយករាជបល្ល័ង្ក

ទៅបាន ហើយតាំងវង្សក្សត្រថ្មីឡើង ហៅថា វង្សហៀវ-ចៀវ គ្រងរាជសម្បត្តិបាន ១០ ឆ្នាំ គឺ តាំងពីពុទ្ធសករាជ ១៤៩៤ ដល់ពុទ្ធសករាជ ១៥០៣ ។

ការច្បាំងដណ្តើមរាជសម្បត្តិ ផ្តួលរំលំរាជវង្សចាស់ តាំងរាជវង្សថ្មី ហើយផ្តួលរំលំគ្នាត ៗ ទៅទៀត ហើយតាំងឡើងថ្មីទៀត មិនមានរាជ្យណាមានជំហររឹងសោះឡើយ នេះហើយធ្វើឲ្យយើងមើលឃើញសភាពវរវឹករបស់ក្រុងចិនយ៉ាងសំបើមក្រៃលែង ជាងសម័យមុនតាំងរាជវង្សថាំងទៅទៀត ។

ការដែលស្រុកចិនកើតចលាចលវរវឹកឡើងនោះ បើកឱកាសឲ្យប្រជាជនមួយពួក ហៅថា គី-តៃ មានសេចក្តីរុងរឿងមានអំណាចឡើងជាឯកក្នុងទ្វីបអាស៊ី ចុងបូព៌ាប្រទេស ពួកគី-តៃ នេះតាំងភូមិប្រទេស ក្នុងដែនមញ្ជូរីភាគខាងត្បូងនៅដែនដីដែលហៅថា លៀវតុង ។ ក្សត្ររបស់ជនពួកនេះ ហៅថា យេលូអាប៉ៅគី ដែលបានគ្រប់គ្រងប្រជាជនពួកនេះនៅក្នុងរវាងពុទ្ធសករាជ ១៤៥០ ដល់ពុទ្ធសករាជ ១៤៧០ ហើយបានដណ្តើមយកខេត្តដែនខាងឈូងសមុទ្រប៉េជិលី ទៅអំពីចិន អ្នកទទួលគ្រប់គ្រងជាដំណតមកហៅថា យេលូតេក្វង គ្រប់គ្រងពួកគី-តៃ នៅក្នុងរវាងពុទ្ធសករាជ ១៤៧០ ដល់ ១៤៩០ ហើយបានជួយឲ្យឈ្មោះ ចេ-គិងថាំង បានគ្រងរាជសម្បត្តិក្រុងចិនម្តង កាល

ពីពុទ្ធសករាជ ១៤៧៩ ហើយក្រុងចិនបានតាំងរាជវង្ស ហៀវ-ជិន ឡើងដូចពោលពីខាងដើមរួចមកហើយ ឯក្រុងចិនបានលើកដែនដីខាងជើងខេត្តប៉េជិលីនិងតាន-ស៊ី ដែលជាទីក្រុងប៉ុក-គិង ឬប៉េកាំងឲ្យទៅយេលូ-តេគួង ៗ ក្នុងឆ្នាំពុទ្ធសករាជ ១៤៨១ យេលូ-តេគួង បានផ្លាស់ទីក្រុងទៅតាំងនៅឯប៉េ-កាំង ហើយក្រុង ប៉េ-កាំង ក៏ចាប់ផ្តើមមានរឿងរ៉ាវសំខាន់ ទើបជាទីក្រុងសំខាន់តាំងពីកាលណោះមក ៗ កាលដែលពួកគី-តៃ តាំងនៅខ្ជាប់ខ្ជួនក្នុងក្រុងប៉េ-កាំងហើយ ក៏ចាប់ផ្តើមច្បាំងលុកលុយដែនដីចិនភាគខាងជើង ហើយតមកក៏ផ្តួលរំលំរាជវង្សចេ-តីថាំងទៅ ហើយចូលគ្រប់គ្រងក្រុងខៃ-ហ្វុងដោយខ្លួនឯង នៅគ្រប់គ្រងជាវេលា ១១ ឆ្នាំ ទើបមានពួកលៀវ-ជី មកវាយដណ្តើមយកក្រុងខៃ-ហ្វុងទៅបានទៀត ដូចពោលរួចមកហើយនោះ ៗ

ការចលាចលវឹកវរដែលពួកគី-តៃ បានធ្វើឲ្យដល់ប្រទេសចិនក្នុងគ្រានេះ រាប់ថាជាការចលាចលយ៉ាងធំក្រៃលែង នាំឲ្យស្រុកចិនក្នុងវេលានោះ បែកខ្ញែកចេញទៅជាច្រើនអាណាចក្រ ៗ ក្នុងសម័យរាជវង្សហៀវ-ចៀវ ដែលបានគ្រប់គ្រងរាជសម្បត្តិនៅក្រុងខៃ-ហ្វុងនោះ ក៏មានអាណាចក្រឯទៀត ១ តាំងជាឥស្សរៈឡើងដល់ទៅ ៧ អាណាចក្រ គឺ

១ — ពួកហួនភាគខាងជើង គ្រប់គ្រងខេត្តថៃនបាន-ស៊ុ តាំងទីក្រុងនៅស្រុកកៃ ហ្វូន តាំងជាឥស្សរៈបានក្នុងរវាងពុទ្ធសករាជ ១៤៩៥ ដល់ ១៥២១ ។

២ — ពួកថាំងគ្រប់គ្រងខេត្តកៀង-ស៊ូ អាំនហួយ និងកៀង ស៊ី តាំងក្រុងនៅស្រុកណាន-គិង តាំងពីរវាងពុទ្ធសករាជ ១៤៨០ ដល់ ១៥១៨ ។

៣ · ពួកណាន គិងគ្រប់គ្រងខេត្តហូ-ប៉េ តាំងពីក្នុងរវាងពុទ្ធសករាជ ១៤៥០ ដល់ ១៥០៦ ។

៤ — ពួកជូគ្រប់គ្រងខេត្តហូ-ណាន តាំងពីក្នុងរវាងពុទ្ធសករាជ ១៤៣៩ ដល់ ១៥០៦ ។

៥ — ពួកវូ-យេះ គ្រប់គ្រងខេត្តជីកៀង តាំងពីក្នុងរវាងពុទ្ធសករាជ ១៤៣៧ ដល់ ១៥២១ ។

៦ — ពួកហួន ទិសខាងត្បូង គ្រប់គ្រងខេត្តក្វាងទុងនិងក្វាង-ស៊ី មានស្រុកកាំង-តាំងជាទីក្រុង តាំងពីក្នុងរវាងពុទ្ធសករាជ ១៤៥០ ដល់ ១៥១៤ ។

៧ — ពួកក្សត្រជាវង្សចាស់ បានគ្រប់គ្រងខេត្តសេ-ឈួននិងខេត្តកៀវ-កៀវ មានស្រុកជិង-ទូ ជាទីក្រុង តាំងពីពុទ្ធសករាជ ១៤៣៤ ដល់ ១៥០៨ ។

វេលាគ្រាណា ព្រះរាជាធិរាជអង្គដែលគ្រប់គ្រងរាជសម្បត្តិនៅក្រុងខៃ-ហ្វុង ទ្រង់ខំប្រឹងព្យាយាមរួបរួមអាណាចក្រអស់នោះមកបញ្ចូលជាមួយគ្នា ពួកអាណាចក្រអស់នោះតែងយល់ទាស់នឹងទទឹងជាដរាប ហើយពួកគី-តៃ ចាំរកឱកាសកំហែងគំរាមអាណាចក្រកណ្ដាលជានិច្ច ទើបគី-តៃនៅវេលានោះ ក៏ក្លាយទៅជាពួកមនុស្សស៊ីឈ្នួល ជួលចូល ឬជួលបង្ហាំង ស្រេចតែខាងណាជួលក៏ទទួលស៊ីឈ្នួលទាំងអស់ ។

## តាំងរាជវង្សស៊ុង

លុះមកដល់ឆ្នាំពុទ្ធសករាជ ១៥០៣ ក្សត្រអង្គក្រោយបំផុតរបស់វង្សហៀវ-ចៀវ ដែលគ្រងស្រុកខៃ-ហ្វុងនោះទិវង្គតទៅ ពួកទាហានទើបប្រកាសតាំងមេទ័ពរបស់ខ្លួនឈ្មោះចៅក្វាងយិនឡើងជាក្សត្រ ទ្រង់ព្រះនាមថា ព្រះបាទ ថៃ-ជី ឡើងគ្រងរាជសម្បត្តិ តាំងរាជវង្សថ្មីហៅថា វង្សស៊ុង ឬសុង ដែលជារាជវង្សធំរបស់ចិនមួយវង្សទៀត ។

ព្រះបាទ ថៃ-ជី គ្រងរាជសម្បត្តិនៅក្នុងរវាងពុទ្ធសករាជ ១៥០៣ ដល់ ១៥១៩ ជាវេលា ១៧ ឆ្នាំ ហើយតាំងពីពេលឡើងគ្រងរាជបល្ល័ង្ក ទ្រង់មានបំណងដ៏ទៀងទាត់ ២ ប្រការគឺរួបរួមអាណាចក្រឡើងជាថ្មីឲ្យបាន ហើយបណ្ដេញពួកគី-តៃ ដែលចូលមកបៀតដែក បង្កាចលា-ចលដល់ប្រទេសចិនជានិច្ចនោះ ឲ្យថយចេញពីអាណាចក្រចិនទៅ ។

ព្រះបាទ ថៃ-ជី ព្រះមហាក្សត្រអង្គថ្មីនេះ ទ្រង់មានព្រះឧស្សាហៈខ្នះខ្នែងក្លាហាន មានព្រះទ័យក្សេមក្សាន្តទូលាយ ទ្រង់ជាមេទ័ពជាទីគោរពបូជារបស់ទាហាន ហើយទ្រង់ជាព្រះរាជាធិរាជ អាចប្រាបប្រាមពួកក្បត់ ធ្វើឲ្យការចលាចលខាងក្នុងប្រទេសស្ងប់រម្ងាប់ទៅបាន ពិតតែទ្រង់មិនមានការសិក្សាយ៉ាងវិសេសមកទេ ប៉ុន្តែទ្រង់សព្វព្រះទ័យនឹងទំនុកបំរុងការសិក្សា សិល្បវិជ្ជា តាំងកេងរៀនរួបរួមគម្រាប់គម្រារបស់ចិនមាន គម្រាខុង-ជីជាដើម ។ កាលការចលាចលស្ងប់រម្ងាប់ទៅហើយ រាជវង្សរបស់ ថៃ-ជី ក៏ចំរើនរុងរឿងឡើងមួយរំពេច ។ អស់កាលវេលាជាងមួយរយឆ្នាំ មុនថៃ-ជី បានគ្រងរាជសម្បត្តិ បណ្តារាស្ត្រទូទៅសឹងមានសេចក្តីស្ងប់ស្ងែងញាប់ញ័រ ខ្លាចអំណាចទាហានចូលមកប្លន់ជាទីបំផុត ដោយមិនបានដឹងពេលវេលាជាមុនឡើយ ។ ព្រះបាទថៃ-ជីទ្រង់រិះរកឧបាយកែអន្តរាយនេះបាន ដោយទ្រង់ព្យាយាមរកបំណាច់រង្វាន់ ឲ្យពួកទាហានបានល្មមគ្រប់គ្រាន់មិនបាច់ឲ្យពួកទាហានដើរប្លន់អ្នកស្រុកទៀត ។ ព្រះបាទថៃ-ជី មិនដែលប្រើឧបាយប្រទូសរ៉ាយអ្នកណាឡើយ ។ នៅវេលាគ្រាមួយមានពួកក្សត្រជាច្រើនអង្គ ធ្វើខុសត្រូវទោស ព្រះបាទថៃ ជី ទ្រង់ចាក់សុកប្រទានឲ្យក្សត្រអ្នកទោសមួយអង្គសោយ ។ ក្សត្រអ្នកទោសអង្គនោះ ស្មានថាជាថ្នាំពុល (ព្រោះក្នុងរាជសំណាក់ចិនវេលាធ្វើទោសសម្លាប់មនុស្ស ច្រើនប្រើវិធីនេះជានិច្ច) ទើបពុក

ផ្គង់សូមជីវិត ព្រះបាទថៃ-ជី ទ្រង់ញញឹមហើយទ្រង់សោយសុខក្នុង ពេជនោះដោយព្រះអង្គឯងទៅ ។

កាលព្រះបាទថៃ-ជី ទើបឡើងគ្រងរាជសម្បត្តិថ្មីៗនោះ ព្រះអង្គទ្រង់ព្យាយាមរួបរួមខេត្តដែនផ្សេងៗ ដែលបែកខ្ញែកពីគ្នានោះមកបញ្ចូលក្នុងអាណាចក្ររបស់ព្រះអង្គក្នុងពុទ្ធសករាជ ១៥០៦ ទ្រង់បានខេត្តហូ-ប៉ើនឹងហូ-ណាន ពុទ្ធសករាជ ១៥០៨ បានខេត្តសេ-ជួន ពុទ្ធសករាជ ១៥១៤ បានស្រុកកាំង-តាំង ពុទ្ធសករាជ ១៥១៨ បានស្រុកណាំ-កាំង ។ តែពួកសត្រូវដែលព្រាបព្រាមមិនទាន់សម្រេច គឺពួកហ្វូននៅទិសខាងជើង ដែលពួកគី-តៃជាអ្នកឧបត្ថម្ភ ហើយចាំតែឱកាសធ្វើការបោលលុករុកដល់ប្រទេសចិនជានិច្ច ។ ឯព្រះបាទថៃ-ជី ទ្រង់ទិវង្គតទៅក្នុងពុទ្ធសករាជ ១៥១៩ នៅវេលាដែលស្តេចចេញទៅធ្វើបង្ក្រាបពួកហ្វូនទិសខាងជើងនោះឯង ។

ព្រះបាទថៃ-ចុង ជាព្រះអនុជរបស់ព្រះបាទថៃ-ជី ឡើងគ្រងរាជ-សម្បត្តិជាដំណតមកក្នុងរវាង ពុទ្ធសករាជ១៥១៩ដល់ពុទ្ធសករាជ១៥៤០ ទ្រង់ចំរើនរាជកិច្ចតាមស្នាមលំអានព្រះជេដ្ឋា ខាងក្នុងស្រុកទ្រង់ទំនុកបម្រុងការសិក្សារៀនសូត្ររបៀបតម្រាប់តម្រា ទាល់តែព្រះរាជបណ្ណា-ល័យបាន មានសៀវភៅចំរើនឡើងដល់ ៨ ហ៊ឺនក្បាល ហើយតម្រាប់តម្រារបស់ខុងជឺក៏បានទទួលលើកដំកើងយ៉ាងខ្ពង់ខ្ពស់ ក្នុងសម័យនេះ ។

# ឃុនសុន្ទរមេធី ញ៉ុង-ស៊ឿង ប្រែ

(តមក)

---

និងប្រែត្រឡប់ឲ្យរូបសព្ទនេះពុំបានឡើយ, រឿងនេះ ចាំខ្ញុំជំរាបលោកឲ្យបានជ្រាប កាលពីល្ងាចម្សិលមិញខ្ញុំមកផ្ទះនេះ ស្រាប់តែឃើញឆ្មាខ្មៅមួយយំញាវៗ នៅមុខខ្ញុំ ហើយកាន់តែរីកធំបន្តិចម្តងៗ ទាល់តែស្មើនក្របី សំដីដែលវានិយាយដាក់កំហិតឲ្យខ្ញុំចាំអម្បាលម៉ាន ខ្ញុំឥតភ្លេចសោះ, ហេតុនេះ សូមលោកអញ្ជើញទៅចុះ ទុកខ្ញុំឲ្យនៅត្រង់កន្លែងដែលនេះបានហើយ"។ លោកអគ្គមហាសេនាមិនថយចេញទៅតាមសំដីអាគមទេ ក៏ត្រឡប់ជាចាប់ផើងកាប៉ែក្រឡាស់ដាក់ឲ្យឈរស្រួលឡើង; គ្រាន់តែដើរជាប់ដល់ដីភ្លាម អានោះឥតឃើញក្រោយបន្តិចសោះ, បាតផើងស្រោតកំឡាំងមានទាំងអម្បាលម៉ានយកមកប្រើទាំងអស់ ឥតសំចៃ, រត់ទៅចូលរាំងក្រាបទូលព្រះរាជាអេស៊ីប តាមដំណើរសព្វគ្រប់, កាលបើបានជ្រាបរឿងបិសាចធ្វើបាបកំផ្លោះ ព្រះអង្គក៏គាំងរឿងឆ្ងល់ជាទីបំផុត ។

លោកសេមសេវខិន ម៉ូហាមេដ ត្រឡប់ចូលទៅក្នុងបន្ទប់កូនស្រីវិញ ឆ្ងល់ហើយហៅសែនមហាឆ្ងល់លើសជាងពីមុនទៅទៀត អំពីរឿងដែលលោកចង់ដឹង ។ លោកបានសួរកូនទៀតថា "នែមេកញ្ញាកល្បី

ល្ងើ! ហេតុអាចគាឲ្យលស់អំពីរឿងកប់ចេកប៉ាងសាម៉ក់ទាំនេះឲ្យអញបានយល់ឆ្ងាយខ្លួយណាយជាន់នេះទៅទៀតបានឬទេ?" ។ ដីកា: ទេលោកឪពុក, ខ្ញុំមិនជាបលោកឪពុកឲ្យហួសអំពីរឿងដែលខ្ញុំបានដកបរូបហើយនោះពុំបានទេ ព្រោះខ្ញុំដឹងតែត្រឹមប៉ុណ្ណោះ ប៉ុន្តែ នេះគ្រឿងសំលៀកបំពាក់ប្ដីខ្ញុំដែលគាត់ដោះដាក់លើកៅអី, សំលៀកបំពាក់នេះប្រហែលជានឹងអាចបំភ្លឺសេចក្ដីឲ្យលោកឪពុកបានយល់ខ្លះពុំខាន; ថាហើយនាងក៏យកឈុត បេវេទទិន មកបង្ហាញឪពុក ។ ទទួលពិនិត្យមើលសព្វគ្រប់រួចហើយ លោកនិយាយថា "ឈុតនេះប្រសិនបើមិនមែនជារបស់ទំនើបយកពីស្រុកមួយស្រុកទេ, អញយល់ថាជាឈុតសម្រាប់មន្ត្រីធំ" ។ កាលលោកបាប់បង្វិលពិនិត្យមើលសព្វគ្រប់ទៅ ប្រទះឃើញដូចជារបស់អ្វីមួយនៅដេរដាក់បញ្ចូលក្នុងចន្លោះស្រទាប់សំពត់ដែលត្រួតគ្នា, លោកក៏ឲ្យគេយកកន្ត្រៃមកឲ្យដើម្បីនឹងកាត់មើល, លុះកាត់ផ្ដាច់រួចហើយ បានឃើញក្រដាសផ្ដត់ គឺជាសៀវភៅដែលខូវេទឌិន-អលី បានឲ្យមកបេវេទឌិនកាលពេលរៀបស្លាប់ ហើយបេវេទឌិនក៏យកមកដេរដាក់បង្កប់លាក់ទុកក្នុងចន្លោះស្រទាប់ឈុតនេះ ដើម្បីរក្សាទុកឲ្យបានបើកថរ ។ សេមសេទខិន ម៉ូហាម្មេទ លុះបានបើកសៀវភៅនោះមើលហើយទើបបានស្គាល់អក្សរខូវេទឌិន-អលី ជាប្អូន ហើយលោកក៏អានចំណងជើងសៀវភៅនោះថា "សម្រាប់កូនខ្ញុំ ឈ្មោះបេវេទឌិនហស្សែន" ។

លោកកំពុងតែត្រិះរិះដូច្នោះ ស្រាប់តែកូនស្រីយកថង់ប្រាក់ដែលនៅក្នុងអាវមកហុចឲ្យលោកទៀត លោកបើកមើលទៅ ឃើញកហាបណៈនៅពេញដូចបាននិយាយរួចមកហើយ, ព្រោះបើបេទ្រេទឌិនហាស្ស៊ីនមានចិត្តសក្តាផកយកកហាបណៈចែកចាយឲ្យគេជាច្រើនក៏ពិតមែន ប៉ុន្តែថង់នោះនៅតែមានកហាបណៈពេញដដែល ដោយអំណាចបុណ្យរបស់បិសាចនិងនាងទេពធីតា ។ លោកបានមើលពាក្យដែលសរសេរលើស្លាកថង់ប្រាក់នោះឃើញមានសេចក្តីថា: "ប្រាក់មួយពាន់កហាបណៈ របស់ជាតិស៊្វីហ្វឈ្មោះអ៊ុសាអ័ក" ហើយបានឃើញពាក្យដែលអ៊ុសាអ័កបានសរសេរមុននឹងបែកគ្នាពីបេទ្រេទឌិនហាស្ស៊ីន មានសេចក្តីដូចខាងក្រោមនេះ "បានប្រគល់ឲ្យបេទ្រេទឌិនហាស្ស៊ីន ដើម្បីជាថ្លៃទំនិញលើកដំបូងកងសំពៅទាំងអស់របស់លោកនូរេទឌិនអលី ជាបិតាដែលបេទ្រេទឌិនហាស្ស៊ីន បានលក់ឲ្យ កាលណាសំពៅទំនិញទាំងនោះនឹងចូលមកចតនៅទីផែនេះ" ។ លោកមើលសេចក្តីនេះមិនទាន់ទាំងចប់ផង ស្រាប់តែស្រែកទ្រហោយំឡើងហើយសន្លប់បាត់មាត់ឈឹងសូន្យទៅ ។

មួយស្របក់ លោកសេមសេទឌិន ម៉ូហាម្មេទ បានដឹងខ្លួនឡើងវិញដោយសារកូនស្រីនិងស្រីបំរើនាំគ្នាមកជួយឈូនរ ។ លោកបាននិយាយទៅកាន់ធីតាថា "កូនស្រីមាសឪពុកអើយ, កូនមិនត្រូវសង្ស័យទេអំពីរឿងដែលឪពុកសន្លប់បាត់មាត់បាត់កនេះ ; ដើមចមដូច្នោះ កូនឯងសឹងតែ

ជឿពុំកើត ; ប្តីដែលបានដេកជាមួយគ្នាពីយប់មិញនេះត្រូវជាបងប្អូនជីដូនមួយ គឺជាកូននូរេទឌិន អលី ។ ប្រាក់មួយពាន់កហាបណៈ នៅក្នុងថង់នេះធ្វើឲ្យអញនឹករលឹកដល់រឿងដែលអញបានបង្កបង្កើតជាមួយនឹងប្អូនសំឡាញ់នោះ គឺជាគ្រឿងបណ្ណាការនៃអាពាហ៍ពិពាហ៍ដែលគាត់បានរៀបចំឲ្យកូនឯង, យើងសូមថ្លែងសេចក្តីអរព្រះគុណយ៉ាងវិសេសចំពោះព្រះជាម្ចាស់, រឿងដ៏ចំឡែកនេះឯងហើយដែលសំដែងឲ្យឃើញនូវឫទ្ធិអំណាចរបស់ព្រះអង្គ!" ។ លោកអគ្គមហាសេនា មើលសំបុត្រប្អូនលោកតទៅទៀត ហើយយកសំបុត្រនោះមកថើបជាច្រើនលើកច្រើនគ្រា ទន្ទឹង ខ្សឹកខ្សួលស្រក់ទឹកភ្នែកស្ទើរសៅញែកបែកទ្រូង ទើបលោកមានវាចាថា "ធ្វើដូចម្តេចហ្ន៎ ទើងឲ្យខ្ញុំបានជួបនូរេទឌិនចំពោះមុខនៅទីនេះ ហើយខ្ញុំនឹងនិយាយលួងលោមផ្សះផ្សាជាមួយនឹងគាត់!" ។

លោកមើលសៀវភៅនោះត្រង់ទំព័រម្ខាងទៀត បានឃើញកំណត់ថ្ងៃ - ខែដែលប្អូនទៅដល់ក្រុងបាល់ស្សូរ៉ា, ថ្ងៃខែរៀបអាពាហ៍ពិពាហ៍ព្រមទាំងថ្ងៃ - ខែ - ឆ្នាំកំណើតរបស់បេទ្រេទឌិនហាស្សន; លុះបានពិនិត្យធៀបគ្នាមើលទៅ ក៏បានឃើញថាត្រូវគ្នានឹងថ្ងៃ - ខែ - ឆ្នាំនៃអាពាហ៍ពិពាហ៍របស់ខ្លួន, ស្របគ្នានឹងឆ្នាំកំណើតនៃធីតាលោកនៅក្រុងកែរ, ទើបលោកមានសេចក្តីកោតស្ញប់ស្ញែងណាស់ចំពោះរឿងនេះ ព្រោះហាក់ដូចជាបានឲ្យដំណឹងគ្នាទៅវិញទៅមក, ក្នុងទីបំផុតលោកពិចារណា

ឃើញថាក្មួយបង្កើត  បានមកជាកូនប្រសាលោកៗ ក៏សំដែងសេចក្ដីរីករាយសប្បាយយ៉ាងក្រៃលែង ។ លោកសេនាបតីកាន់សៀវភៅទឹងស្វាកជង់ប្រាក់យកទៅក្រាបបង្គំទូលព្រះរាជា, ទ្រង់បានព្រះរាជានុញ្ញាតលើកទោសទោលចំពោះរឿងដែលកន្លងទៅហើយ ។ លុះបានជ្រាបការណ៍សព្វគ្រប់ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ត្រាស់ឲ្យរាជបណ្ឌិតសរសេររឿងនោះទាំងអស់ ដើម្បីទុកឲ្យមានជាតំណាងជាប់តទៅក្នុងអនាគតកាល ។

គ្រានោះ លោកសេមសេទឌិន ម៉ូហាម្មេទ មិនយល់សោះអំពីរឿងដែលកូនប្រសាលោកបាត់ខ្លួនទៅនេះ, ប៉ុន្តែ លោកនៅតែសង្ឃឹមរាល់ៗពេលថាមុខជានឹងបានឃើញមកដល់វិញក្នុងថ្ងៃណាមួយពុំខាន ទើបលោកត្រាំរង់ចាំមើលផ្លូវ ដើម្បីនឹងឱបក្រសោបថ្និតថ្នមកូនប្រសា ។ លុះត្រាំចាំដោយឥតប្រយោជន៍យ៉ាងនេះអស់មួយសប្ដាហ៍, លោកក៏ចាត់បំរើឲ្យដើរស៊ើបសួររកពាសពេញទាំងក្រុងកៃរ៉ូ, ប៉ុន្តែ ឥតបានដំណឹងបន្តិចបន្តួចសោះ, លោកមានសេចក្ដីតប់ប្រមល់ព្រួយប្រាណរំខានចិត្តជាទីបំផុត មិនដឹងជាធ្វើដូចម្ដេចនឹងបានដឹងរឿងនោះ ។ លោកអត់ត្រាំពុំបានទើបលាន់មាត់ថា "ឱហ្ន៎! រឿងនេះបានចំជាប្លែកមែនរឿងបែបនេះ ឥតមាននរណាធ្លាប់បានដឹងបានឮម្ដង-សោះ!" ។

ដោយពិចារណារករឿងដែលនឹងកើតមាននៅក្នុងអនាគតពុំឃើញប្រាកដជាយ៉ាងណា ទើបលោកអគ្គមហាសេនាចាប់សរសេរកត់ត្រាទុក

អំពីរបៀបផ្ទះសម្បែងរបស់លោក ក្នុងពេលនោះគឺដូចម្តេចខ្លះ គឺដំណើររបៀបភាពាហ៍ពិពាហ៍ដែលកន្លងហួសទៅហើយ មានបែបផែនយ៉ាងណា បន្ទប់ធំនិងបន្ទប់តូចសម្រាប់គូនស្រី គាត់តែងដោយគ្រឿងលំអដូចម្តេច សំលៀកបំពាក់និងថង់ប្រាក់របស់បេទ្រេខិនដាក់ត្រង់ណា លោកបានកត់ត្រាទុកទាំងអស់ រួចហើយបេលោកយកឈុត ព្រមទាំងថង់ប្រាក់និងសំលៀកបំពាក់ដែលនៅក្នុងទីនោះមកវេចខ្ចប់ស្រួលបួល ហើយយកទៅចាក់សោទុកក្នុងហិបលើ ។

ក្នុងវេលាយូរថ្ងៃបន្តិចមក ជីតាលោកសេមសេទខិន ប៉ូហាម្មេទ ដឹងថាខ្លួនមានផ្ទៃពោះ; លុះទ្រទ្រង់គភ៌គ្រប់ ៩ ខែហើយនាងក៏ប្រសូត្រកូនប្រុសមួយ ។ គេបានចាត់ចែងរកមេដោះម្នាក់ព្រមទាំងខ្ញុំកំដរប្រុសស្រីជាច្រើន សម្រាប់បីទាំផ្គត់ផ្គង់ទារក តាមសមគួរដល់ឋានៈជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ជីតាបានឲ្យឈ្មោះថា កាយិប ។

កាលកាយិបកុមារ មានវ័យវឌ្ឍនាការចំរើនធំឡើងបានអាយុប្រហែល ៧ ឆ្នាំ លោកសេនាបតីសេមសេទខិនម៉ូហាម្មេទ មិនបង្ហាត់បង្រៀននៅផ្ទះទេ បានយកទៅឲ្យចូលសាលារៀនផ្ញើទុកដាក់នឹងគ្រូម្នាក់ដែលមានកិត្តិយសខ្ពង់ខ្ពស់ ហើយឲ្យបាវពីរនាក់សម្រាប់ជូនទៅសាលានិងនាំមកផ្ទះវិញរាល់ៗថ្ងៃ ។ កាយិបតែងលេងជាមួយនឹងពួកសិស្សជាគូកនទាំងឡាយតាមធម្មតា សិស្សទាំងអស់នោះសុទ្ធតែមានឋានៈទន់ទាប

ទើបត្រូវធ្វើសេចក្ដីគោរពកោតក្រែងអាយ៉ិបគ្រប់ៗគ្នា; ហើយទុកអាយ៉ិបហាក់ដូចជាគ្រូដែលមានបង្គាប់បញ្ជាកិច្ចការគ្រប់ជំពូកបាន ។ កាលបើសិស្សទាំងឡាយមានសេចក្ដីគោរពខ្លាចយ៉ាងនេះ អាយ៉ិបក៏ឡើងដៃកើតមានះរឹងត្អឹងព្រហើនក្រអឺតក្រអោងកោងកាចឥតខ្លាចនរណាសោះ តែងធ្វើទុកបុកម្នេញឲ្យគេក្ដៅក្រហាយជានិច្ច គឺវាត្រួតត្រាបំបាក់គេទាំងអស់ ហើយប្រសិនបើមាននរណាមួយហ៊ានដដែកតវ៉ាទទឹងទាស់ នឹងបំណងរបស់វាៗ ដេរប្រទេចផ្ដាសាដោយប្រការផ្សេងៗ ហើយជួនកាលមានដល់ទៅវាយដំប្រចំពាក់គេទៀតផង ។ ដល់ទៅក្នុងទីបំផុត សិស្សទាំងអស់អត់ទ្រាំពុំបាន នាំគ្នាចូលទៅដំរាបប្ដឹងគ្រូបង្រៀនអំពីដំណើរអាយ៉ិបព្រហើនកោងកាចពេក ។ មុនដំបូងអាចារ្យនិយាយសម្រះសម្រួលលួងលោមសិស្សទាំងនោះឲ្យខំអត់ធ្មត់ទៅ, ប៉ុន្តែលុះឃើញអាយ៉ិបរឹតតែឡើងដៃធ្វើបាបគេខ្លាំងឡើងៗ ទាំងខ្លួនអាចារ្យឯងក៏អត់ទ្រាំពុំបាន ទាន សេចក្ដីលំបាកនឹងចិត្តណាស់នឹងអំពើល្ហានពានដូច្នោះ ទើបនិយាយនឹងសិស្សទាំងឡាយថា: "នែអ្នកទាំងអស់គ្នា! យើងឃើញច្បាស់ប្រាកដថាអាយ៉ិបជាកុមារព្រហើនណាស់, យើងនឹងប្រាប់ឧបាយមួយដើម្បីនឹងធ្វើវាឲ្យអាម៉ាស់មុខ ហើយឲ្យវាលែងធ្វើបាបអ្នកទាំងអស់គ្នា តាមសេចក្ដីស្មានរបស់យើងថា កាលបើអ្នកទាំងឡាយធ្វើតាមឧបាយនោះទៅ វាមុខជានឹងលែងមករៀនក្នុងសាលានេះបានទៀតហើយ ។

ថ្ងៃស្អែក, ដល់ពេលដែលនឹងត្រូវប្រជុំគ្នាលេងតាមធម្មតា អ្នកទាំងអស់គ្នាត្រូវឈរពោមព័ទ្ធអាយ៉ិច ហើយឲ្យនរណាម្នាក់តាប់និយាយឡើងដោយសំឡេងយ៉ាងខ្លាំងពេញទំហឹងថា :

"ឥឡូវនេះ ពួកយើងត្រូវប្រជុំគ្នាលេង, ប៉ុន្តែត្រូវមានខសន្យាគឺអ្នកដែលចង់លេងជាមួយនឹងយើង គប្បីប្រាប់ឈ្មោះខ្លួនទីងៈ ឈ្មោះឪពុកម្ដាយឲ្យបានដឹងទៅវិញទៅមក ទើបយើងបើកឲ្យចូលលេងជាមួយផង, បើអ្នកណាមិនព្រមប្រាប់ឈ្មោះដូចបាននិយាយហើយនោះទេ យើងមិនព្រមឲ្យអ្នកនោះលេងជាមួយឡើយ" ។

សិស្សទាំងឡាយ លុះបានទទួលបញ្ជាយអំពីសំណាក់គ្រូយ៉ាងនេះហើយ ក៏នាំគ្នាវិលទៅកាន់លំនៅរៀងៗ ខ្លួនដោយសេចក្ដីរីករាយ ។

ស្អែកឡើង គ្រាដែលចួបជុំគ្នាអស់ហើយ សិស្សទាំងនោះតាំងផ្ដើមធ្វើកិច្ចដែលគ្រូបានពន្យល់រួចហើយ គឺឈរពោមពេមព័ទ្ធអាយ៉ិចហើយសិស្សម្នាក់តាប់ប្រកាសឡើងថា "មកវ៉ុយ យើងនាំគ្នាលេងល្បែងមួយ ប៉ុន្តែបើអ្នកណាមិនប្រាប់ឈ្មោះខ្លួនទីងឈ្មោះម្ដាយឪពុក យើងមិនត្រូវឲ្យអ្នកនោះលេងចូលឡើយ" ។ គេឆ្លើយយល់ព្រមទាំងអស់គ្នាទាំងអាយ៉ិចក៏យល់ព្រមដែរ ។ ខណៈនោះសិស្សដដែល ក៏តាប់សួរឈ្មោះគ្មួកខទាំងអស់តាមលំដាប់ហូរហែ គេបានឆ្លើយត្រឹមត្រូវតាមសេចក្ដីសន្យាខាងដើម ចំណែកខាងអាយ៉ិច កាលគេសួរដល់ឈ្មោះខ្លួន

ហើយ ក៏ឆ្លើយថា "ខ្ញុំឈ្មោះអាយ៉ិប ម្ដាយខ្ញុំឈ្មោះ ដាមជីបូគេ (នារីធោមយង់) ឪពុកឈ្មោះ សេមសេចឌិន ម៉ូហាម្មេទ មានងារស័ក្តិជាអគ្គសេនាបតីនៃព្រះរាជា" ។

ទិមិត្តតែឮពាក្យនេះភ្លាម កុមារទាំងឡាយស្រែកឡើងថា "នែអា-យ៉ិប អ្នកនិយាយអ្វីដូច្នេះ? មិនមែនឈ្មោះឪពុកអ្នកឯងទេ គឺជាឈ្មោះជីតាអ្នកទេតើ" ។ អាយ៉ិបឆ្លើយវិញដោយប្រទេក្រគខឹងថា "ទេ! ទេព្ត បំភាន់អ្នកទាំងអស់គ្នាហើយ ពួកអ្នកហ៊ាននិយាយថាលោកសេមសេចឌិន ម៉ូហាម្មេទមិនមែនជាឪពុកយើង!" ។ សិស្សទាំងឡាយឆ្លើយព្រមទាំងអស់សំណើចផងថា "មិនមែនទេ ខុសស្រឡះហើយ លោកសេមសេចឌិន ម៉ូហាម្មេទត្រូវជាជីតារបស់អ្នកទេតើ ហេតុនេះអ្នកទឹងចូលលេងជាមួយពួកយើងពុំបានឡើយ ពួកយើងក៏ប្រយ័ត្នខ្លួនមិនចូលទៅជិតអ្នកដែរ ជាដូច្នោះហើយ គេនាំគ្នាដកឃ្លាថយចេញឆ្ងាយពីអាយ៉ិប បំអកចំអន់លេងហើយសើចហោៗតែគ្នាគេ អាយ៉ិបមានសេចក្ដីអាម៉ាស់មុខ កើតទុក្ខទោមនស្សក្ដៅក្រហាយឈឺចិត្តខ្លាំងណាស់ ព្រោះការបំអកឡកឡឺយមើលងាយរបស់សិស្សទាំងឡាយ រកធ្វើអ្វីគេពុំកើត ក៏តាំងយំតែម្នាក់ឯង ។

អាចារ្យ បានស្ដាប់ដឹងរឿងនោះជាក់ប្រាកដចំពោះខ្លួន ទើបនិយាយនឹងអាយ៉ិបថា "នែអាយ៉ិប អ្នកមិនទាន់ដឹងថាលោកសេម-

សេទឌិន ម៉ូបះមេទ មិនមែនជាឪពុកអ្នកទេឬ? លោកត្រូវជាជីតាអ្នក គឺជាឪពុកនាងនារីធោមឃ័ន្ធម្តាយអ្នកទេតើ ទាំងយើងក៏ដូចអ្នកដែរ មិនបានស្គាល់ឈ្មោះឪពុករបស់អ្នកទេ, យើងដឹងរឿងតែប៉ុណ្ណោះថា: ព្រះកជាទ្រង់បានផ្សំផ្គុំរៀបចំធ្វើអាពាហ៍ពិពាហ៍ម្តាយអ្នកជាមួយនឹងបុរសគម្នាក់ជាគង្វាលសេះរបស់ព្រះអង្គ ប៉ុន្តែមានបិសាចមួយមកដេកជាមួយនឹងនាងទៅវិញ; រឿងនេះឯងហើយដែលនាំបណ្តាលឲ្យអ្នកប្រកាន់មានះរឹងត្អឹងកាចឃោរឃៅធ្វើបាបគ្រូនទាំងឡាយ ដរាបមកដល់ពេលនេះ ។

អាយិបកុមារ ត្រូវគេចំអកដៀមដាមឲ្យដូច្នេះហើយទឹកឈឺចិត្តណាស់ ចេញពីសាលាយ៉ាងប្រញាប់ត្រឡប់ទៅផ្ទះយំបណ្តើរផង ។ ទៅដល់ភ្លាម ចូលទៅក្នុងបន្ទប់ម្តាយ ។ ឃើញកូនយំកើតទុក្ខមុខក្រៀមក្រំដូច្នោះ ក៏ខ្សឹកខ្សួលអួលអន់សម្រក់ទឹកភ្នែក ហើយសួរគេដំណើរដើមទង៍យ៉ាងស្រេក ។ អាយិប ឆ្លើយទាំងយំអណ្តឺតអណ្តក ព្រោះតឹងណែនដើមទ្រូងដោយសេចក្តីឈឺចិត្ត បានប្រាប់ម្តាយអំពីហេតុការ·ម៉ាសុខ ព្រោះតែមានគេមើលងាយដូចបាននិយាយហើយខាងដើម ។ រួចហើយអាយិបសួរម្តាយថា "អ្នកម្តាយ! សូមអ្នកប្រាប់ខ្ញុំឲ្យត្រង់កុំលាក់ ចុះនរណាដែលត្រូវជាឪពុកខ្ញុំ?" ។ នាងនារីធោមឃ័ន្ធតបវិញថា "កូនប្រុសពន្ធក! ឪពុកអ្នកគឺលោកសេមសេទឌិន ម៉ូហាមេទហ្នឹងឯង

ហើយដែលនឹងទុកក្រសោបបីបម្អ្នកលំៗថ្ងៃ' ។ អាយ៉ិច 'អ្នកម្ដាយ អ្នកប្រាប់ខ្ញុំមិនត្រង់ មិនមែនឪពុកខ្ញុំទេ ជាឪពុកអ្នកម្ដាយទេតើ ចំណែកខាងខ្ញុំ ជាកូនអ្នកណាវិញ ?" ។ ម្ដាយបានឮសំដីកូនដូច្នោះ នឹកឃើញដល់ពេលក្រីដែលតាំងពីចាប់រៀបមង្គលការហើយមក ក៏នៅមេម៉ាយអស់កាលដ៏យូរ មិនដឹងជាប្ដីនាងនោះព្រាត់ប្រាសបាត់ទៅឯណា នឹកស្រណោះស្រណោចអាណោច អធ័មយំខ្សឹកខ្សួលអួលអន់សម្រែកទឹកភ្នែក ដោយសេចក្ដីសោកស្ដាយអាឡោះអាល័យប្ដីសំឡាញ់ ដែលប្រាសនិរាសឃ្លាតបាត់ទៅរកមុខបាតពុំឃើញ នឹងហាមាត់ប្រាប់កូនដូចម្ដេចទៀតក៏មិនរួច ។

ក្នុងខណៈ ដែលនារីធាមយំកំពុងសោកបោកខ្លួននៅក្បែរអាយ៉ិច លោកសេដ្ឋីសេខឌិន ម៉ូហាមេទ ក៏ចូលទៅតាន់ហើយសួររកហេតុសេចក្ដីទុក្ខព្រួយនៃអ្នកទាំងពីរ ។ នារីបានសារសព្វដំរាបបិតា អំពីរឿងអាយ៉ិចតាមហូរហែសព្វគ្រប់ ។ ដំណើរនេះនាំបណ្ដាលឲ្យលោកអគ្គមហា-សេនាកើតសេចក្ដីក្ដុកក្ដួលអួលដើមទ្រូងទប់ពុំបាន ក៏តាំងសោកសង្រេងសង្រែជាមួយគ្នា ដោយពិចារណាឃើញថាអ្នកទាំងពួងនិយាយបង្ខូចកេរ្ដិ៍ឈ្មោះកូនស្រីលោក លោកក៏នឹកសង្វេគស្រយុតចិត្ដណាស់ចំពោះរឿងនោះឯង ។ លុះគិតឃើញដូច្នោះហើយទើបលោកចូលទៅកាន់ព្រះបរមរាជវាំង ក្រាបថ្វាយបង្គំប្រណំទូលទៀបព្រះបាទានៃព្រះករុណា

ជាម្ចាស់ជីវិត ទូលសូមព្រះរាជានុញ្ញាតធ្វើដំណើរទៅកាន់ខេត្តច័ណ្ឌពៃន
បច្ចិមប្រទេស ហើយទៅកាន់ក្រុងបាល់សូកជាដើមផង ដើម្បីស្វះស្វែង
រកបេះដូងឧិនហស្ស៊ីនគេយលោកឲ្យឃើញ ដ្បិតអ្នកក្រុងទាំងមូលយល់
គ្រប់គ្នាថា ៗ បីសាចមួយបានដេករួមសង្វាសជាមួយនឹងនារីធោមយង់គូន
ស្រីលោក នាំឲ្យលោកទឹកទោមនស្សត្រូវបង់ជាទីបំផុត ។ ព្រះរាជា
ក៏មានព្រះហឫទ័យអាណិតលោកអគ្គមហាសេនា បានទ្រង់ព្រះរាជា-
នុញ្ញាតប្រោសប្រទានតាមបំណង ហើយបានចេញសុភអក្សរសាសន៍
ឡាយព្រះហស្តលេខាប្រថាប់ព្រះរាជលញ្ជករព្រះរាជទានចំពោះអគ្គមហា-
សេនា សេចក្តីក្នុងសុភអក្សរសាសន៍នោះគឺថ្វាយដំណឹង ឲ្យដំណឹង
ដល់ព្រះរាជាទាំងឡាយនិងសព្វមុខមន្ត្រីក្នុងតំបន់នានា ដែលបេះដូងឧិន
ហស្ស៊ីនបានចូលទៅនៅអាស្រ័យ ដើម្បីឲ្យយល់ព្រមអនុញ្ញាតបើកឲ្យ
លោកអគ្គមហាសេនាទៅរកទៅដោយស្រួលបួល កុំបីចាប់ទោសអ្វីស
ដំណើរដូចម្តេចឡើយ ។

លោកសេម៉េសឧិនម៉ូហម្មេទ រកទឹកពាក្យថ្លែងអំណរព្រះគុណ
ចំពោះព្រះរាជាពុំឃើញ គ្រាន់តែក្រាបប្រណម្យចំពោះព្រះភក្ត្រទ្រង់
ជាតំរប់ពីរដងប៉ុណ្ណោះ ប៉ុន្តែទឹកភ្នែកដែលហូរហៀរចាកនេត្រាលោកមក
នោះគឺសំដែងសេចក្តីដឹងព្រះគុណដ៏លើសលុបជំនួសពាក្យសំដី របស់
លោក ៗ រួចហើយ លោកថ្វាយបង្គំព្រះរាជាលាត្រឡប់ទៅផ្ទះវិញ

ដល់ហើយក៏រៀបចំគ្រឿងប្រដាប់ប្រដាបំរុងដំណើរទៅដោយរួសរាន់ ។ ការប្រុងប្រៀបឲ្យរៀបចំអីវ៉ាន់ទាំងនោះ រួចរាល់សព្វគ្រប់ក្នុងរវាង ៤ ថ្ងៃ លោកក៏ចេញទៅមួយអន្លើដោយនាងនារីតាមយង់ និងអាយ៉ិចថៅរបស់លោក ។ ដំណើរទាំងនោះត្រាច់ទៅអស់ ១៩ ថ្ងៃ ឥតឈប់សម្រាកនៅកន្លែងណាមួយឡើយ លុះដល់ថ្ងៃគំរប់ ២០ បានដល់ទៅកន្លែងវាលស្មៅមួយដ៏ស្អាតនៅឆ្ងាយបន្តិចអំពីទ្វារក្រុងដាម៉ាស៍ ទើបឈប់បោះជំរំក្បែរមាត់ព្រែកមួយដែលហូរកាត់ទីក្រុង ហើយមានទំហំមាត់ច្រាំងជុំវិញស្អាតចេញគួរឲ្យពិតពិលរមិលមើល ។

លោកសេមសេទឌិនមូហាម្មេទបានគិតសម្រេចថា លោកនឹងនៅសម្រាកក្នុងទីនោះចំនួន ២ ថ្ងៃសិនដល់ថ្ងៃទី ៣ សឹមធ្វើដំណើរតទៅទៀត ។ ពេលនោះលោកបើកអំណាចដល់ពួកមនុស្សដែលទៅតាមលោក ឲ្យចូលទៅក្នុងក្រុងដាម៉ាស ដើម្បីស៊ើបដំណឹងក្រុងជូនជាបទ្រេតឌិនហ្សូទនៅទីនោះ; ដោយបានអំណាចច្បាប់ដូច្នេះ អ្នកខ្លះក៏ដើរលេងកំសាន្តសប្បាយមើលទីក្រុងដែលខ្លួនធ្លាប់ឮគេនិយាយថា ជាទីក្រុងស្តុកស្តម្ភថ្កើង ។

(មានត)

# រឿងសាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា (នូ-កន)

(តមក)

---

ទាំង ៣ នាក់ដែលធ្វើខុសក្នុងកិច្ចការបញ្ជូនចូលទៅ ខណៈនោះឡៅពីទៅដល់កណ្ដាលផ្លូវ បានឮកិត្តិសព្ទថា ចៅហ្វាយស្រុកគេង-ជីវ ចេញសំបុត្រឲ្យស៊ីហចាប់ខ្លួន បើខឹងស្រុកទៅឲ្យដល់ស្រុកខុនគួនក្រែងមិនទាន់ ឡៅពីដឹងថា ឡៅកេងដែលជាចៅហ្វាយស្រុកកែងជីវជាសែជាមួយគ្នាទើបគិតថា បើដូច្នោះយើងត្រូវចូលទៅអាស្រ័យនៅនឹងឡៅកេងនៅសិនចុះទើបផុតភ័យ គិតហើយក៏នាំកួនអ៊ូតៀវហ៊ុយនឹងបក្ខពួកចូលទៅរកឡៅកេងនៅស្រុកកែងជីវ ដល់ហើយក៏ពណ៌នាប្រាប់សេចក្ដីនៃរឿងខ្លួនឲ្យឡៅកេងស្ដាប់ ឡៅកេងដឹងក្នុងសំបុត្រចៅហ្វាយស្រុកគេងជីវ ត្រូវគ្នានឹងពាក្យ ឡៅពីប្រាប់ដូច្នោះ ក៏នឹកអាណិតឡៅពីពន់ពេក ព្រោះជាសែជាមួយគ្នាហើយជាពូជព្រះវង្សផង ទើបឡៅកេងបំពួនខ្លួនឡៅពីកួនអ៊ូតៀវហ៊ុយឲ្យនៅក្នុងផ្ទះ ។

និយាយពីខន្ទី ១០ នាក់នោះ ព្រះចៅឡេនតេទ្រង់ព្រោសប្រាណណាស់ ទឹងស្រដីនិយាយកិច្ចការអ្វីក៏សំរេចដូចចិត្ត ទើបតៀវកុងតៀវយៀង ខន្ទីទាំង២ នាក់ ឲ្យបម្រើទៅនិយាយការដល់មន្ត្រីនាយទាហានដែលបានទៅក្រាបពួកអាចោរជួតក្បាលលឿងនោះថា បើអ្នកឯណា

មានទ្រព្យរបស់ជាមាសប្រាក់ ហើយយកទៅជូននាយចៅហ្វាយយើង នោះនាយចៅហ្វាយយើង នឹងជួយក្រាបពិតទូលឲ្យបានឡើងយសស័ក្តិ តាមគុណបំណាច់ បើអ្នកឯណាមិនបានគិតគួរសមនឹងនាយចៅហ្វាយយើងទេ នឹងទូលបង្ខុសឲ្យថយយសស័ក្តិខានធ្វើមន្ត្រីខ្ញុំរាជការតទៅ ៗ ខណៈនោះហង់ហ៊ូកូនឹងជូហ៊ុជានាយមហាហានធំ បានស្តាប់សំដីបរិពោលជូហ៊ុនោះ ក៏ពស់អធ្យាស្រ័យណាស់មិនទទួលធ្វើតាមពាក្យពន្យល់នោះ ៗ តៀវគុង តៀវយៀងក៏គេរៀងទូលញុះញង់ព្រះចៅឡេងតេឲ្យដកហូតងារហង់ហ៊ូកូនឹងជូហ៊ុចេញចាកតំណែងរាជការ ព្រះចៅឡេងតេក៏ទ្រង់ធ្វើតាមហើយតាំងតៀវគុង តៀវយៀងឲ្យឡើងទីជាមន្ត្រីធំទាំងអស់ ៗ វេលានោះរាជការផែនដីក៏ប្រែត្រឡប់ផ្តេសផ្តាសជាខ្លាំងណាស់ ។ អស់អាណាប្រជានុរាស្ត្រពាសករទាំងឡាយ ក៏កើតក្តៅក្រហាយទូទាំងព្រះរាជធានី ៗ

ឈ្មោះក្ងូសងពួកចោរជួតក្បាលលឿង រត់ទៅនៅស្រុកតៀងសា បញ្ចុះបញ្ចូលបបួលពួកអ្នកស្រុក ដើរលួចប្លន់ដណ្តើមទ្រព្យ កាប់សម្លាប់អាណាប្រជានុរាស្ត្រទាំងពួងជាច្រើនតំបន់ គ្មានអ្នកឯណានឹងរិះគិតសង្កត់សង្កិនឲ្យរាបទាបនោះឡើយ ឈ្មោះតៀវគី តៀវស៊ុន នៅស្រុកយីយ៉ុង ក៏តាំងបញ្ចុះបញ្ចូលពួកបក្ខបានជាច្រើនហើយ គិតក្បត់ តៀវគីនោះតាំងខ្លួនធ្វើជាស្តេច - តៀវស៊ុនជាសេនាបតីធំធ្វើការ

អាក្រក់ទៅផ្សេងៗ ពួកចៅហ្វាយស្រុកទាំងពួងដឹងការណ៍ ក៏ធ្វើសំបុត្របកប្តឹងចូលទៅស្រុកក្រុងជាច្រើនគ្រា ខទ្ទី ១០ នាក់បិទសេចក្តីនោះទុកមិនបានក្រាបបង្គំទូលព្រះចៅឡូនតេទ្រង់ជ្រាបសោះ ។

មានកាលមួយថ្ងៃ ព្រះចៅឡូនតេស្តេចចេញទៅប្រពាតសួនច្បារទ្រង់សោយសុភជ័យនៅទីនោះ ឯខទ្ទី ១០ នាក់ក៏អង្គុយផឹកនៅមុខព្រះទីនាំង ។ ខណៈនោះ ឡោតោជាក៏លៀនស្តេច ដឹងថាពួកចោរកំរើបក្បត់ឡើងទៀត ព្រះចៅឡូនតេ មិនបានទ្រង់ជ្រាប ឡោតោមានចិត្តបារម្ភណាស់ក៏តាមស្តេចទៅក្នុងសួន ព្រះចៅឡូនតេទតឃើញក៏ត្រាស់សួរថា ឡោតោធ្វើទឹកមុខបែបមានភ័យចូលមកមានការអ្វី ? ឡោតោក្រាបបង្គំទូលថា ព្រះអង្គមិនទ្រង់ជ្រាបឬទេ ? ឥឡូវនេះ គ្រប់ខេត្តខ័ណ្ឌទាំងពួង កើតចលាចលទៀតហើយ ស្រុកគង់អន្តរាយជាប្រាកដ ហេតុម្តេច ព្រះអង្គមកគង់សោយសុខសប្បាយដូច្នេះ ៗ ព្រះចៅឡូនតេទ្រង់ត្រាស់ថា ខេត្តខ័ណ្ឌទាំងពួងកើតចលាចល យើងប្រើសេនាទាហានទៅបង្ក្រាបរាបអស់ហើយ ហេតុអ្វីក៏មកនិយាយដូច្នេះ ៗ ឡោតោក្រាបបង្គំទូលថា ខេត្តខ័ណ្ឌទាំងពួងដែលកើតចលាចលគ្រានេះ ពីព្រោះខទ្ទី ១០ នាក់និយាយការពារការទាំងពួង មិនប្រកបដោយផ្លូវយុត្តិធម៌សោះ ទូលព្រះបង្គំជាខ្ញុំដឹងសេចក្តីប្រាកដណាស់ លុះនឹងស្ងៀមមិនក្រាបទូល ក៏ហាក់ដូចមិនមានផ្លូវកតញ្ញូដល់ព្រះអង្គ វេលានោះខទ្ទី ១០

នាក់បានឮព្រះឡៅគោក្រាបបង្គំទូលដូច្នោះ ក៏ភ័យណាស់ លុះចូលទៅជិតមុខព្រះទីនាំង ធ្វើឧបាយជាដោះម្លូក ហើយស្រែកយំទូលថា ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលបានធ្វើជាខ្ញុំក្រោមលម្អងធូលីព្រះបាទសព្វថ្ងៃនេះ សឹងតាំងចិត្តជាសុចរិត ខំធ្វើរាជការរក្សាផែនដីនោះយ៉ាងទៀងត្រង់ណាស់ តែថា អស់ពួកនាហ្មឺនធំៗ ទឹងឡៅគោឃើញថា ព្រះអង្គទ្រង់ប្រោសប្រាណក៏មានចិត្តឥច្ឆាស្អប់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ទើបគិតឧបាយរករឿងឡើងមកក្រាបបង្គំទូលបង្ខុស បើដូច្នេះ ទឹងធ្វើរាជការតទៅគង់មិនបានរួចអាយុជីវិតឡើយ ទូលព្រះបង្គំជាខ្ញុំទាំងឡាយសូមក្រាបថ្វាយបង្គំលាលែងធ្វើរាជការ ចេញទៅធ្វើស្រែចម្ការចិញ្ចឹមជីវិតចុះ ឯទ្រព្យរបស់ទាំងប៉ុន្មានសូមលើកថ្វាយព្រះអង្គ សូមឲ្យទ្រង់ចែករំលែកឲ្យពួកសេនាទាហានដែលធ្វើរាជការ ។

ព្រះចៅឡៅគោបានទ្រង់ព្រះសណ្ដាប់ពួកខន្ទីពិតទូលដូច្នោះក៏ទ្រង់ព្រះពិរោធក្រោធទឹងឡៅគោខ្លាំងណាស់ត្រាស់ថា ខ្លួនឯងគ្រាន់តែជាទីពីលៀនប៉ុណ្ណោះ សូម្បីកន្ទីរាំនៅផ្ទះសម្បែងរបស់ឯង ក៏គង់មានបាវព្រាវល្អមប្រើប្រាស់ជាធម្មតា ខ្លួនអញជាក្សត្រសោយរាជសម្បត្តិជាម្ចាស់ផែនដី ក៏គប្បីឲ្យមានមនុស្សប្រើប្រាស់នៅខ្វះ ហេតុអ្វី ឯងមកបុស្សាឲ្យអញឈឺចិត្តដូច្នេះ ដែលឯងសំដែងខ្លួនជាគតញ្ញូនោះ អញមិនឃើញផងសោះ ត្រាស់ហើយទ្រង់បង្គាប់ពេជ្ឈឃាដខាងក្នុងឲ្យចាប់ខ្លួន

ឡៀវគោទៅសម្លាប់ ពេជ្ឈឃាដក៏ចូលចាប់ខ្លួនឡៀវគោចេញទៅ ឡៀវគោស្រែកចំពោះព្រះភក្ត្រថា ដែលទ្រង់ត្រាស់បង្គាប់ឲ្យសម្លាប់ទូលព្រះបង្គំជាខ្ញុំនោះមិនបានស្ដាយជីវិតទេ ទូលព្រះបង្គំជាខ្ញុំស្ដាយតែកជសម្បត្តិព្រះចៅហានកូវ ដែលសាងសន្សំមកអំពីដើមបាន ៤០០ ប្លាយឆ្នាំហើយ ស្រុកទេសមិនដែលកើតចលាចលសោះ គ្រានេះមុខជានឹងអន្តរាយសាបសូន្យប្រាកដ ពេជ្ឈឃាដក៏ដឹកនាំឡៀវគោចេញទៅដល់ទីកន្លែងពិឃាដ លើកដាវឡើងនឹងកាប់ ខទូលគាន់តាំឃើញសូរមកស្រែកឃាត់ថា កុំកាលសម្លាប់ចាំខ្ញុំចូលទៅទូលស្នើព្រះចៅឡេនគេឲ្យឃើញទោសខុសត្រូវសិន គាន់តាំក៏ចូលទៅក្រាបបង្គំគាល់ដល់ទីសួនផ្កា ហើយទូលសួរថា ឡៀវគោធ្វើខុសពីអ្វីបានជាព្រះអង្គទ្រង់ឲ្យនាំទៅសម្លាប់ ព្រះចៅឡេនគេបានទ្រង់ព្រះសណ្ដាប់គាន់តាំទូលសួរដូច្នោះ ទើបត្រាស់ថា ឡៀវគោជាមនុស្សចិត្តហើសពុំមានសេចក្ដីគិត យកសេចក្ដីមិនពិតមកនិយាយញុះញង់ទម្លាក់ទោសមកលើខន្ទី ១០ នាក់ដែលមានយសសក្ដិជាធំ ហើយស្ដីទ្រគោះឲ្យយើងទៀត ។ គាន់តាំទូលថា បណ្ដាណាហ៊ានតូចធំទូអស់អាណាប្រជានុរាស្ត្រគ្រប់ខេត្រខ័ណ្ឌទាំងអស់ សុទ្ធតែមានសេចក្ដីក្ដៅក្រហាយជាច្រើនណាស់មានចិត្តស្អប់ចង់ស៊ីសាច់ពួកខន្ទី ១០ នាក់ ឲ្យអស់ទៅ ហេតុម្ដេចព្រះអង្គទ្រង់កប់ការស្រឡាញ់ពួកខន្ទីនោះខ្លាំងម៉្លេះ ពួកខន្ទីនេះនឹងមានគុណបំណាច់យ៉ាងណា បានជាព្រះអង្គតាំងឲ្យធ្វើជាមន្ត្រីធំៗ

ទូលព្រះបង្គំជាខ្ញុំឃើញមិនសមគួរសោះ ។ ១ ទៀត ហង់ស៊ី ខន្ទី ក៏ប្រែចិត្តក្បត់ ប្រែកលឲ្យហ្វាយបួលទិនពួកចោរដួតក្បាលលៀន មានអ្នកឯទៀត ប្តូលមកក្រាបទូលព្រះអង្គ ព្រះអង្គមិនចង់ជំរះគេឲ្យ ឃើញរៀបត្រង់ ព្រះអង្គក្រែងធ្វើជានៅស្ងៀមដែលព្រះអង្គធ្វើដូច្នេះ ទិនចង់ឲ្យរាជសម្បត្តិអន្តរាយឬអ្វី ?

ព្រះចៅទ្បេនគេត្រាស់តបថា មានអ្នកមកក្រាបទូលថា ហង់ស៊ី ជាក្បត់នោះមិនមែនសោះ ឯខន្ទីទាំង ១០ អ្នកនេះយើងបានចំនុកបំរុង អស់ពីចិត្តជាប្រាកដ បើហង់ស៊ីជាក្បត់គង់មានខ ៩ នាក់នៅត្រង់ល្អឬយ៉ាង ហោចណាស់គង់មានម្នាក់ ឬ ២ នាក់នៅត្រង់ល្អទិនយើង គង់ទិននាំ ពត៌មានឲ្យយើងដឹង ។

គាន់តាំឃើញថា ព្រះចៅទ្បេនគេស្រឡាញ់កប់ការខន្ទី ១០ នាក់ លើសលុប ទិនប្រាព្ធទូលនាំហេតុឲ្យវែងទៅទៀតក៏មិនជាប្រយោជន៍ ជាក់ច្បាស់ គាន់តាំខឹងណាស់យកក្បាលបោកនិងក្រឹតទាល់ ដែល ស្តេចគង់នោះទាល់តែបែកក្បាលហូរឈាម ព្រះចៅទ្បេនគេទ្រង់ព្រះ ក្រោធខ្លាំងណាស់ ត្រាស់ឲ្យពេជ្ឈឃាដខាងក្នុងចាប់យកខ្លួន គាន់តាំ ទិនឡៅគោ ដែលនាំទៅសម្លាប់នោះយកទៅដាក់គុកទាំង ២ នាក់ វិញ លុះវេលាយប់ខន្ទី ១០ នាក់គិតគ្នាហើយហៅភូឃុំមកបង្គាប់ថា

បើដល់ពេលពាក់កណ្តាលអធ្រាត្រ ឲ្យលបសម្លាប់គាត់តាំងនឹងឡៀងគោ ចេញពុះ គូឃុំក៏ទៅធ្វើតាមខទី៩បង្គាប់ ។

ហើយខទី ១០ នាក់ក៏តែងជាសំបុត្រព្រះរាជគ្រមាស់ទៅដល់ស៊ុន-ក្វៀនថា ត្រាស់ឲ្យស៊ុនក្វៀនទៅឈរស្រុកតៀងសា ហើយឲ្យបង្ក្រាបគ្រូសេង ដែលជាពួកចោរសេះចេញឲ្យរាបទាប ស៊ុនក្វៀនដឹងក្នុងសំបុត្រព្រះរាជគ្រមាស់ហើយ ក៏លើកពលទៅបង្ក្រាបពួកចោរ លុះបានរាបទាបហើយ ក៏បកសំបុត្របួលទៅក្រាបទូលព្រះចៅឡេនតេ។ ទ្រង់ជ្រាប ទើបទ្រង់ព្រះតំរិះថា ស៊ុនក្វៀនមានសេចក្តីគាប់ប្រសើរក្នុងរាជការស្រុកកាំងតែហជាខែត្រឯក ទើបឲ្យតែងព្រះរាជគ្រមាស់បង្គាប់ស៊ុនក្វៀនឲ្យទៅឈរស្រុកកាំងតែហ ឲ្យឡៀងនឹងជាទីចៅហ្វាយស្រុកអ៊ីជីវ ឲ្យលើកទាហានទៅរាយកៀវតីកៀវស៊ុនដែលតាំងខ្លួនជាស្តេចយីយ៉ុង ។

ឯឡៀងកេងដឹងក្នុងព្រះរាជគ្រមាស់ថា ឡៀងនឹងត្រូវទៅច្បាំងនឹងកៀវតី កៀវស៊ុនដូច្នោះក៏សរសេរសំបុត្រឲ្យឡៀងពីកាន់ទៅរកឡៀងនឹងក្នុងសំបុត្រនោះថា ឡៀងកេងឡៀងពីទំងឡៀងនឹងជាសែជាមួយគ្នា សុំឲ្យឡៀងពីធ្វើការសឹកជាមួយផង ឡៀងនឹងដឹងក្នុងសំបុត្រដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ។

(មានត)

## មធុរភាសិត

### លោកគ្រូព្រះវិភទ្ធញ្ញាណ សោម- ឡុប រៀបរៀង

(តមក)

---

ព្រះសារីបុត្រត្រិះរិះពិចារណាថា លោកនេះ បានមកបួសហើយក៏នៅតែរងទុក្ខវេទនាដោយអត់អាហារដដែល បើដូច្នោះ ចាំដល់ថ្ងៃព្រឹកស្អែក សូមអាត្មាអញនឹងនាំលោកនេះទៅបិណ្ឌបាតលមើល ក្រែងជួនជាមានគេជ្រះថ្លាដោយសារអាត្មាអញ គេនឹងនាំគ្នាយកចង្ហាន់មកដាក់បាត្រខ្លះ លុះព្រឹកស្អែកឡើង ព្រះសារីបុត្រក៏បបួលលោកនោះថា នែលោសកតិស្សៈ មកទៅបិណ្ឌបាតជាមួយនឹងខ្ញុំ ។ ឯលោសកតិស្សៈក៏បានទៅជាមួយ លុះចូលទៅដល់ស្រុកភូមិ ពួកអ្នកស្រុកនោះបានឃើញព្រះសារីបុត្រក៏មានសទ្ធាជ្រះថ្លា នាំគ្នាយកចង្ហាន់មកប្រគេនដាក់បាត្រ លុះក្រឡេកឃើញលោសកតិស្សៈនៅពីខាងក្រោយ ក៏បាត់ជ្រះថ្លានាំគ្នាយកចង្ហាន់ត្រឡប់ចូលទៅក្នុងផ្ទះវិញ ។ ព្រះសារីបុត្រឃើញដូច្នោះក៏គិតពិចារណាថា ទុកម្មរបស់លោកនេះទេតើ ដែលនាំមិនឲ្យគេជ្រះថ្លា ទើបមានពាក្យប្រាប់ថា នែលោសកតិស្សៈ ចូរលោកទៅនៅចាំខ្ញុំឯសាលាក្រៅភូមិសិនចុះ ខ្ញុំនឹងចូលទៅបិណ្ឌបាតតែម្នាក់ឯងវិញ បើបានចង្ហាន់សូមខ្ញុំឲ្យគេនាំយកទៅប្រគេនឆាន់ ។ លោកនេះ ក៏ព្រមនៅចាំលើសាលានោះ ។ លុះព្រះសារីបុត្រចូលទៅក្នុងស្រុកនោះម្តងទៀត

ជនទាំងនោះក៏ជ្រះថ្លានាំគ្នាយកចង្ហាន់មកដាក់បាត្រ ហើយនិមន្តឲ្យឆាន់ក្នុងទីនោះ មុននឹងឆាន់លោកក៏បានប្រាប់ថា អ្នកកល់គ្នាមើលចាត់ចែងចង្ហាន់យកទៅឲ្យលោកកូនសិស្សអាត្មាឆាន់ផង លោកនៅចាំឯសាលាក្រៅឯណោះ ៗ ទើបឧបាសកម្នាក់ទទួលថា កុំព្រួយព្រះទ័យលោកម្ចាស់ និមន្តលោកម្ចាស់ឆាន់តាមសប្បាយចុះ ខ្ញុំព្រះករុណានឹងឃានានាំចង្ហាន់យកទៅប្រគេនលោកនោះ ហើយក៏នាំចង្ហាន់យកទៅប្រមុងនឹងប្រគេនលោកនោះដោយពិត ប៉ុន្តែ ផលអកុសលកម្មរបស់ភិក្ខុនោះមកបិទបាំងគំនិតត្រឡប់ជាដឹកនាំបង្វែងចិត្តអ្នកនោះឲ្យនាំចូលទៅក្នុងទីដទៃវិញ ហើយបរិភោគអាហារចំណីនោះអស់លើង ហើយត្រឡប់មកផ្ទះវិញ ៗ ឯព្រះសារីបុត្រក៏ឥតបានសួររឿងនោះឡើយ លុះធ្វើភត្តកិច្ចរួចហើយ ក៏លាអ្នកស្រុកទៅវិញ ទៅដល់សាលាក៏សួរភិក្ខុនោះថា លោកបានឃើញគេនាំយកចង្ហាន់មកឲ្យដែរឬទេ ៗ ភិក្ខុនោះទូលតបថា មិនឃើញទេ ៗ ព្រះសារីបុត្រក៏គិតថា ឧកម្មរបស់លោកនេះធ្ងន់ណាស់តើ ទើបនាំលោកនោះទៅថ្វាយព្រះពរព្រះបាទពិម្ពិសារ តាមរឿងនោះដោយសព្វគ្រប់ ៗ ព្រះបរមក្សត្រក៏មានព្រះទ័យអាណិតក្រពេក ទើបទ្រង់ឲ្យរាជបុរសចាត់ចែងភេសជ្ជៈចំនួន ១ បាត្រ លើកមកប្រគេនព្រះសារីបុត្រ ៗ ទទួលចាប់មាត់បាត្រម្ខាង ឲ្យភិក្ខុនោះចាប់មាត់ម្ខាង ហើយប្រាប់ថា ចូរលោកឆាន់ភេសជ្ជៈនេះចុះ តែត្រូវប្រុងប្រយ័ត្នកុំឲ្យ

កំពប់ឡើយ ៗ ភិក្ខុនោះធំបានឆាន់ឆ្អែតស្កប់ស្កល់ ៗ វេលានោះ បើព្រះសារីបុត្រមិនជួយចាប់មាក់បាត្រម្ចាស់ផង មុខជានឹងកំពប់មិនខាន ព្រោះកម្លាំងកម្មរបស់ភិក្ខុនោះខ្លាំងពេកណាស់ ៗ មុខគួរឲ្យអាស្ចារ្យ អាណិតភិក្ខុនោះក្រៃពេក ចាប់ដើមតាំងពីបួសមកកាលណា មិនដែលបានអាហារអ្វីឆាន់ឆ្អែតម្ដងសោះ ទើបតែបានឆាន់ឆ្អែតម្ដងកុងពេលនោះឯង លុះឆាន់រួចហើយ ព្រះសារីបុត្រក៏ថ្វាយព្រះពរលាព្រះភជាំនាំភិក្ខុនោះត្រឡប់ទៅវត្តវិញ ៗ គ្រាក្រោយមកភិក្ខុនោះមានចិត្តសង្វេគខ្លាំងក៏ខំប្រឹងការនាធម៌ គ្រាតែបានសម្រេចអរហត្តផល ហើយចូលនិព្វានក្នុងវេលានោះឯង ៗ

នេះហៅថា **ភ័យអ្វីមិនស្មើភ័យខ្លាចបាប** ៗ

គ្រង់បទថា **លាភអ្វីមិនស្មើលាភគឺតរោគបៀតបៀនប្រាណ** ៗ

សេចក្ដីអធិប្បាយថា **លាភ** គឺការបានទ្រព្យសម្បត្តិបានយសសក្ដិជាធំ តែលាភទាំងនេះមិនហៅថាលាភឧត្ដមប្រសើរទេ ការដែលមិនមានរោគបៀតបៀនកាយ ទើបហៅថា លាភឧត្ដមប្រសើរ សមដូចពុទ្ធភាសិតថា អារោគ្យា បរមា លាភា ការមិនមានរោគចាត់ជាបរមលាភ , គឺបុគ្គលណាមួយដែលកើតមកក្នុងលោកនេះ មិនសូវមានរោគអាពាធព្យាធិសេចក្ដីឈឺចាប់ក្នុងកាយ ច្រើនប្រកបដោយសេចក្ដី

សុខសប្បាយយ៉ាងនេះ ទើបហៅថា បុគ្គលមានលាភឧត្តម បើអ្នកដែលមានទ្រព្យសម្បត្តិ មានយសស័ក្តិធំហើយ ប៉ុន្តែបន្តិចឈឺនេះ បន្តិចឈឺនោះឥតបានសេចក្តីសុខសព្វវេលាសោះ យ៉ាងនេះហៅថាបុគ្គលគ្មានលាភវិញ មួយយ៉ាងទៀត បុគ្គលដែលកើតមកទាល់ក្រគ្មានយសស័ក្តិនេះ ប៉ុន្តែច្រើនប្រកបដោយកម្លាំងខ្លាំង មានព្រលឹងព្រលះជាតធំទ្រលុកទ្រលន់ស្រួលបួលទាំងមិនសូវមានជម្ងឺកាត់អ្វីមកបៀតបៀនយ៉ាងនេះក៏ហៅថា បុគ្គលមានលាភឧត្តមវិញដែរ ។ នេះហើយហៅថា លាភអ្វីមិនស្មើលាភឥតរោគបៀតបៀនប្រាណ ។

ត្រង់បទថា ទានអ្វីមិនស្មើទានធម៌ទេសនា នោះសេចក្តីអធិប្បាយថា ទាននោះលោកចែកដោយសង្ខេបមាន ២ យ៉ាង គឺ : អាមិសទាន ១ ធម្មទាន ១ ។ អាមិសទានបានខាងការឲ្យបច្ច័យ ៤ មានចីវរបច្ច័យជាដើម បច្ច័យណាមួយគឺឲ្យដល់បព្វជិតឬដល់គ្រហស្ថ ឬដល់សត្វតិរច្ឆានហៅថាអាមិសទាន តាំងនោះសោតបូជាក្បួនផ្កាជាដើមដល់ព្រះរតនត្រ័យ ក៏រួបរួមហៅថា អាមិសទានទាំងអស់ ឬហៅថា អាមិសបូជាវិញក៏បាន ។

៦ធម្មទាន ការឲ្យធម៌គឺសំដែងធម៌ឲ្យគេស្តាប់ ឬបង្ហាត់បង្ហាញបាលីព្រមទាំងអដ្ឋកថា ឲ្យគេបានចេះដឹងស្គាល់ការណ៍ខុសត្រូវបុណ្យបាបគុណទោសតាមផ្លូវព្រះពុទ្ធវចនៈឬបុរសគេស្តាប់ធម៌នេះហៅថាធម្មទាន ។

បណ្ដាទានទាំងពីរនេះ ធម្មទានជាកំពូលនៃទានទាំងអស់ប្រសើរជាងទានទាំងពួង ៗ ព្រោះហេតុអ្វីបានជាលោកលើកធម្មទានប្រសើរជាងអាមិសទាន ព្រោះហេតុថាធម្មទានជាមធ្យោបាយសម្រាប់បង្ហូរនូវអាមិសទាន គឺថាបុគ្គលដែលចេះដឹងរៃលកតាក់តែងធ្វើអាមិសទានបាន ក៏ព្រោះតែបានឮបានស្ដាប់ធម៌គឺច្បាប់ដែលប្រាប់ពន្យល់ផលប្រយោជន៍ ដូចប្រាប់ពន្យល់ថា ជនណាធ្វើបុណ្យយ៉ាងនេះ នឹងបានផលយ៉ាងនោះៗ បុគ្គលបានស្ដាប់បានឮដូច្នោះហើយ ទើបបានតាក់តែងធ្វើបុណ្យមានឲ្យទានផ្សេងៗជាដើមទៅបាន ៗ ព្រោះហេតុនោះ បានជាលោកលើកធម្មទាននេះថាជាទានប្រសើរជាងអាមិសទានទាំងអស់ សមដូចព្រះពុទ្ធដីកាថា :

សព្វទានំ ធម្មទានំ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ
សព្វរសំ ធម្មរសោ ជិនាតិ
តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

ធម្មទានឈ្នះទានទាំងអស់ ការត្រេកអរនឹងធម៌ឈ្នះការត្រេកអរទាំងអស់ រសឆ្ងាញ់ពីសារបស់ធម៌ ឈ្នះរសឆ្ងាញ់ពិសាទាំងអស់ ការអស់ទៅនៃតណ្ហា ទើបឈ្នះនូវទុក្ខទាំងអស់បាន ៗ នេះហៅថា

**ទានអ្វីមិនស្មើទានធម៌ទេសនា ។**

ត្រង់បទថា បញ្ញាអ្វីមិនស្មើបញ្ញាអ្នកបានព្រះអរហត្ត នោះ មានសេចក្តីអធិប្បាយថា បុថុជ្ជនខ្លះក្នុងលោកនេះមានបញ្ញាចេះដឹងសិល្បសាស្ត្រផ្សេងៗ តាំងផ្លូវលោកផ្លូវធម៌ក៏ឃើញចំណាប់ចំនួនប្រាកដដល់ក្អែក ជនទាំងពួង ពិតមែនណាស់ថៃ ប៉ុន្តែបញ្ញារបស់បុថុជ្ជននេះ បានតែសំដែងឫទ្ធិអំណាចខាងក្រៅឲ្យគេខ្លាចឲ្យគេកោតឲ្យគេសរសើរបាន គ្រាន់បើប៉ុណ្ណោះទេ នឹងយកបញ្ញាបែបនោះមកកាប់ផ្តាច់កិលេសតណ្ហាក្នុងសន្តានរបស់ខ្លួនពុំបាន មានតែបញ្ញាអ្នកបានព្រះអរហត្ត ទើបអាចកាត់ផ្តិលផ្តាច់កិលេសតណ្ហាបាន ព្រះសព្វញ្ញុពុទ្ធក៏ទ្រង់ត្រាស់សរសើរបញ្ញានេះ ជាអនេកប្រការថា អ្នកមានទ្រព្យសម្បត្តិកប់សែនលានកោដិ ក៏មិនស្មើនឹងអ្នកមានបញ្ញាឡើយ បញ្ញានេះវិសេសបំផុតក្នុងលោក ព្រោះហេតុនោះអម្បូរពោធិសត្វទាំងឡាយ កាលបើបានកសាងកុសលណាមួយ ៗ ហើយក៏តែងប្រាថ្នាចំពោះត្រង់បញ្ញាមួយប៉ុណ្ណោះឯង ដូចកាលព្រះអង្គនៅជាព្រះបាទវេស្សន្តរបរមពោធិសត្វនៅឡើយ ទ្រង់លើកជាលីកណ្ហា ជាបុត្រសង្សារឲ្យជាទានតាជូជក លើកព្រះនាងមទ្រីជាអគ្គមហេសីឲ្យជាទានឥន្ទ្រព្រាហ្មណ៍ ឥតមានស្តាយស្រណោះ អាឡោះអាល័យឡើយ ។ ព្រះបរមពោធិសត្វទ្រង់មានព្រះរាជសទ្ធា ហ៊ានព្រះរាជទានរបស់សំឡាញ់យ៉ាងនេះ ក៏ទ្រង់មិនត្រូវការនឹងសម្បត្តិអ្វីដទៃឡើយ ទ្រង់ត្រូវការប្រាថ្នាប្តូរយកតែបញ្ញាមួយមុខប៉ុណ្ណោះឯង

ដោយទ្រង់ព្រះតម្រិះយល់ឃើញថា បើបញ្ញាកើតឡើងហើយ គាបនឹងដេញសេចក្ដីល្ងង់ទៅ ងងឹតក្នុងសន្ដានបាន ប្រៀបដូចពន្លឺប្រទីបជាដើម តែភ្លឺឡើងក្នុងវេលាណាហើយ ក៏អាចដេញងងឹតឲ្យឃ្លាតខ្ចាត់ខ្ចាយពេញទៅឆ្ងាយបាន នេះហៅថា **បញ្ញាមិនស្មើបញ្ញាអ្នកបានអរហត្ត ។**

ត្រង់បទថា **អត្ថអ្វីមិនស្មើអត្ថបរមត្ថព្រះអភិធម្ម** នោះមានសេចក្ដីអធិប្បាយថា អត្ថឯទៀតៗ មានច្រើន តែមិនស្មើនឹងអត្ថបរមត្ថព្រះអភិធម្មទាំង ៤ គឺ ចិត្ត ១ ចេតសិក ១ រូប ១ និព្វាន ១ នោះឡើយ ព្រោះអត្ថទាំង ៤ នេះជាសុខុមភាព ល្អិតជ្រាលជ្រៅពេកណាស់ ហួសវិស័យបុថុជ្ជននឹងចាក់ធ្លុះបាន មានតែអង្គព្រះសព្វញ្ញុពុទ្ធទើបត្រាស់ដឹងបានដោយច្បាស់លាស់ មិនមានសល់ចន្លោះ មិនមានភាន់ច្រឡំ ៗ លុះព្រះអង្គទ្រង់បានត្រាស់ជាបច្បាស់នូវអត្ថនេះហើយ ទើបទ្រង់សំដែងទុកមក ក៏មានអ្នកដែលចេះដឹងតាមព្រះអង្គផងនោះ ដោយកម្រពេកណាស់ តិចគ្នាពេកណាស់ មានជនខ្លះគិតមិនធ្លុះមិនធ្លាយ ដរាបដល់តែលង់ស្មារតីទៅជាមនុស្សឆ្កួតក៏មាន ៗ ដោយហេតុនោះបានជាលោកពោលថា **អត្ថអ្វីមិនស្មើអត្ថបរមត្ថព្រះអភិធម្ម ។**

ចប់មាតិកាទាំង ៨ បទតែប៉ុណ្ណេះ ។ (នៅមានត)

# បរិយាយសាមគ្គី

## របស់ព្រះទេពមុនី យូរ ប៊ុណ្ណ

*ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ*

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ (ដោយសេចក្ដីគោរព) ។

ពេលនេះ អាត្មាភាពសូមដកស្រង់យកពុទ្ធភាសិតថា "សុខា សង្ឃស្ស សាមគ្គី" នេះ មកសំដែង ដើម្បីជាសវនាការដល់អស់លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយដូចតទៅនេះ :

ពាក្យថា "សុខា សង្ឃស្ស សាមគ្គី" ប្រែថា "សេចក្ដីព្រមព្រៀងគ្នានៃពួកសង្ឃឬគណៈ នាំមកនូវសេចក្ដីសុខ" ។

សង្ឃសព្ទ ក្នុងទីនេះ សំដៅយកពួកក្រុម គ្រួសារ ស័ង្គម ឬប្រទេសមួយៗហៅថាសង្ឃ: ។ ការព្រមព្រៀងគ្នា មូលមិត្ត ជិតស្និទ្ធ រួបរួមគ្នា ស្រុះស្រួលគ្នា ស្រុះចិត្តគ្នា ស្មើដៃគ្នា ក្នុងការធ្វើកិច្ចអ្វីៗ ហៅថាសាមគ្គី ។ រួមសេចក្ដីថា "ការព្រមព្រៀងគ្នា ក្នុងក្រុមនីមួយៗ នាំមកនូវសេចក្ដីសុខ" ។

ការព្រមព្រៀងគ្នាក្នុងក្រុម ឬគណៈនីមួយៗ នេះជាសាធារណៈទូទៅទាំងគ្រហស្ថ- បព្វជិត ទាំងគតិលោក- គតិធម៌, គតិទាំងពីរនេះ

បើមិនមានសាមគ្គីធម៌នៅក្រស័យផងទេ  កិច្ចការអ្វីមួយដែលត្រូវធ្វើ ត្រូវនិយាយ ត្រូវគិត ក៏មិនបានសម្រេចប្រយោជន៍ប៉ុន្មានឡើយ ។

ការព្រមព្រៀងរួបរួមគ្នានេះ ជាគុណសម្បត្តិមួយយ៉ាងវិសេសក្នុងលោក សូម្បីព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់សំដែងអំពីសាមគ្គីនេះទុកជាពាក្យមួយ សម្រាប់អ្នកកាន់ព្រះពុទ្ធសាសនាដែរ ។

អស់លោក ៖- អ្នកសប្បុរសទាំងឡាយ  ពេលនេះជាពេលគួរដល់យើងត្រូវកសាងប្រទេសជាតិឲ្យមានពន្លឺស្មើ  កិត្តិយសខ្ពស់ត្រឡុងត្រឡាយ  ដោយការបណ្តុះសាមគ្គី  ខាងការរៀនចំណេះវិជ្ជា និងការស្វែងរកទ្រព្យសម្បត្តិឲ្យកាន់តែមានកំឡាំងខ្លាំងឡើងហើយ បណ្តាជនជាតិទាំងឡាយក្នុងពិភពលោកនេះ ឥតមានរូបណាមួយ ចង់នៅក្រោមបង្គាប់នៃសេចក្តីល្ងង់ខ្លៅក្រីក្រលំបាក ថោកទាបទេ  អ្នកប្រទេសណាដែលធ្លាក់ខ្លួនទៅជាមនុស្សល្ងង់ខ្លៅក្រីក្រលំបាក ថោកទាបហើយ អ្នកប្រទេសនោះ គេតែងរើខ្លួនគេឲ្យរួចពីកណ្តាប់ដៃនៃសេចក្តីល្ងង់ខ្លៅក្រីក្រលំបាក ថោកទាបជាដរាប ។

មុនដំបូងយើងត្រូវរួបរួមគ្នារក្សាជាតិ ទំនុកបម្រុងជាតិ គោរពជាតិ លើកដំកើងជាតិ  ស្រឡាញ់ជាតិជាមុន  កុំឲ្យបែកប្រេះឆាស្រាំសាមគ្គីជាតិ  កុំប្រកាន់បក្សពួកថា ពួកនេះ ពួកនោះឡើយ ត្រូវឲ្យនឹកឃើញថាជាតិមួយម៉ាត់  ដែលជាប់សាច់សាលោហិតសែស្រឡាយជាមួយគ្នា

តែម្យ៉ាង បើយើងនៅតែប្រកាន់បក្សពួកថា ពួកនេះ ពួកនោះ ឲ្យបែកប្រេះឆាស្រាំសាមគ្គីជាតិខូចហើយ ធ្វើម្តេចឡើយនឹងឈានជើងដើរទៅកាន់អារ្យធម៌ជាន់ខ្ពស់បាន ។

ហេតុនេះ យើងជាខេមរជាតិ ដែលជាជាតិធ្លាប់មានល្បីឈ្មោះក្នុងពង្សាវតារលោកពីដើមនឹងគេដែរ ត្រូវប្រួបរួមគ្នាបណ្ដុះសាមគ្គីធម៌នេះឲ្យកើតមានឡើង ទាន់ពេលសម័យដែលបើកឱកាសឲ្យ ។

## សាមគ្គីនេះបែកចេញជា ៣ យ៉ាង គឺ :

១ កាយសាមគ្គី ព្រមព្រៀងដោយកាយ

២ – វចីសាមគ្គី ព្រមព្រៀងដោយវាចា

៣ – មនោសាមគ្គី ព្រមព្រៀងដោយចិត្ត ។

១ កាយសាមគ្គី ព្រមព្រៀងដោយកាយនោះ គឺ :

គ្រប់ប្រទេសទាំងអស់ក្នុងលោក ដែលនឹងត្រូវស្ទុះឡើងចាកភាពថោកទាបបាននោះ មិនមែនត្រូវអាស្រ័យកំឡាំងរបស់ឯកជនម្នាក់ៗ ទេ ។ ដែលពិតនោះ គឺត្រូវអាស្រ័យកំឡាំងរបស់ជនរួមជាតិទាំងមូល ស្រុះស្រួលចិត្តគំនិតគ្នា មិនប្រឆាំងប្រណាំងប្រជែងកេងកាតដណ្តើមយកមុខមាត់តែម្នាក់ឯង ឲ្យទាល់តែបែកឆ្ងាយប្រេះឆាស្រាំសាមគ្គីខូចទេ, ឯការបែកសាមគ្គីនេះ ជាទោសមួយយ៉ាងធំបំផុតក្នុងលោក សូម្បីអ្នកកាន់

ព្រះពុទ្ធសាសនាក៏ដូចគ្នា ៗ ដូចមានរឿងដំណាលក្នុងគម្ពីរពុទ្ធសាសនាថា សម័យនោះ ពួកភិក្ខុនៅក្នុងក្រុងកោសម្ពី គ្រាន់តែមានហេតុបន្តិចបន្តួចប៉ុណ្ណោះសោះ ក៏បណ្ដាលនាំឲ្យវិវាទប្រកួតប្រកាន់គ្នា ទាល់តែបែកសាមគ្គីលែងមើលមុខគ្នាត្រង់ ពួកស្ដេចមន្ត្រីទាំងទាយក ឧបាសក ឧបាសិកា មកនិយាយអង្វរលោមទោមឲ្យស្រុះស្រួលគ្នាយ៉ាងណា ក៏មិនព្រមស្ដាប់ ទាល់តែគេលែងជ្រះថ្លា លែងប្រគេនចង្ហាន់ដាក់បាត្រគ្រប់ដំបន់ទាំងអស់ ព្រះពុទ្ធជាម្ចាស់ទ្រង់ឃាត់ហាមទៀត ក៏មិនព្រមស្ដាប់នៅតែបះបោសមុខរឹងយកឈ្នះម្នាក់ៗ ទាល់តែទ្រង់យាងចេញពីទីនោះ ទៅគង់ក្នុងព្រៃបាលិលេយ្យៈអស់ចំនួន ៣ ខែ ។ ភិក្ខុទាំងនោះក៏មិនបានសម្រេចមគ្គផលអ្វីឡើយ ។

មួយទៀត ដូចពួកស្ដេចលិច្ឆវីក្នុងដែនវជ្ជី ជាស្ដេចមានឫទ្ធិ មានអានុភាពច្រើន ព្រមព្រៀងគ្នារក្សាអបរិហានិយធម៌ ៧ ប្រការម៉ាំមួន ពេលមួយព្រះបាទអជាតសត្រូ មានព្រះបំណងនឹងទៅច្បាំងដណ្ដើមយកដែននោះ តែដោយអំណាចពួកវជ្ជីក្សត្រទាំងនោះ មានសាមគ្គីធម៌ប្រតិបត្តិអបរិហានិយធម៌ម៉ាំមួន ព្រះបាទអជាតសត្រូក៏មិនអាចនឹងទៅជះជាន់ញាំញីច្បាំងដណ្ដើមយកបានឡើយ ។ លុះដល់មកពេលខាងក្រោយ ពួកវជ្ជីក្សត្របែកសាមគ្គីលែងទុកចិត្តគ្នា មិនយូរប៉ុន្មាន ទើប

ព្រះបាទអជាតសត្រូវ លើកទ័ពទៅច្បាំងដណ្ដើមយកដែននោះមកធ្វើជាចំណុះព្រះអង្គបាន ។

រឿងនេះមិនមកអំពីអ្វី គឺមកតែអំពីការបែកសាមគ្គីនាំឲ្យវិនាសអន្តរាយប្រទេសជាតិ ភោគសម្បូរ ឬទ្ធិអំណាចអានុភាពរបស់ខ្លួន ទៅជាខ្ញុំគេព្រោះទោសបែកសាមគ្គី ។

ហេតុនេះ សូមអស់លោក-អ្នករួមជាតិទាំងឡាយ ត្រូវពួតដៃគ្នារក្សាសាមគ្គីធម៌នេះឲ្យរឹងមាំ កុំប្រកួតប្រកាន់ដណ្ដើមយកបក្សពួកឡើយ, ត្រូវក្រោកឈរឡើងឲ្យត្រង់ខ្លួន កុំខ្ជិលច្រអូសពុញព្រាន់ ឬគេច ការងារឲ្យគ្រប់ដៃ ទាំងរៀនចំណេះវិជ្ជាឲ្យបានគ្រប់គ្នាឡើង ដើម្បីមិនធ្វើប្រទេសជាតិ សាសនា ព្រះមហាក្សត្រឲ្យមានតម្លៃ កុំឲ្យប្រទេសបន្ទោសយើងទៅថ្ងៃក្រោយ អ្នកណានៅស្រុកណា ភូមិណា សង្គមណា ត្រូវបបួលគ្នាអង្គាសប្រាក់កាសតាមគំនិតច្រើន កសាងមន្ទីរពេទ្យសម្រាប់ព្យាបាលរោគ ទាំងសាលាបង្រៀនអក្សរសាស្ត្ររបស់ជាតិ សម្រាប់បណ្ដុះចំណេះវិជ្ជាដល់កុមារកុមារីក្នុងស្រុកក្នុងភូមិរបស់យើង ឲ្យបានគ្រប់គ្រាន់ឡើង ព្រោះចំណេះវិជ្ជាអក្សរសាស្ត្រនេះ ជាថ្មើមប្រទាក់ជីវិតរបស់ប្រទេស ឯឫទ្ធិអំណាច អានុភាព យសស័ក្តិ ភោគសម្បូរ ទាំងកើតឡើងនោះ អាស្រ័យមកពីចំណេះវិជ្ជាអក្សរសាស្ត្ររបស់ជាតិទាំងអស់ សម្រាប់រក្សាកេរ្តិ៍ឈ្មោះខ្លួន, ដូចជាអំបិលជាជាតិប្រៃ អំពិលជាជូររក្សា

ជាតិរបស់ខ្លួនទុក បើទុកជាគេយកទៅដាក់ទៅបន្ទុកនៃស្រុកណាមួយ មាន ដូរផ្តើមជាដើម អំបិលក៏នៅតែរក្សាជាតិរបស់ខ្លួនឲ្យនៅជាប្រៃដដែល យ៉ាងណាមិញ វិជ្ជាអក្សរសាស្ត្ររបស់ជាតិ បើរលត់រលាយហើយ ប្រទេសជាតិ សាសនា ព្រះមហាក្សត្រ បុព្វអំណាច គុណភាព គោត- សម្ព័ន្ធ គឺត្រូវយើងរក្សាទុកកុំឲ្យបាត់រសជាតិដូច្នោះដែរ ។

មួយទៀត ឧបាយដែលនឹងកសាងប្រទេស ការពារប្រទេស ឃើញយានប្រទេសនោះ ប្រជាជនអ្នករួមជាតិ ត្រូវធ្វើតាមរបៀបនេះគឺ:

ក ត្រូវគោរពជាតិ, ស្រឡាញ់ជាតិ, លើកដំកើនជាតិ, កុំក្បត់ជាតិ ។

ខ - ត្រូវគោរពសាសនា, ស្រឡាញ់សាសនា, លើកដំកើនសាសនា, កុំក្បត់សាសនា ។

គ - ត្រូវគោរពព្រះមហាក្សត្រ, ស្រឡាញ់ព្រះមហាក្សត្រ, លើកដំកើនព្រះមហាក្សត្រ, កុំក្បត់, កុំប្រមាថ, កុំមើលងាយព្រះមហាក្សត្រ ។

ឃ - យុវជន (កុមារកុមារី) ត្រូវចូលខ្លួនទៅសាលាសិក្សាប្រគល់ខ្លួនជាសិស្ស, ទើបត្រូវបង្ហាត់បង្ហាញហ្វឹកហ្វឺនបង្ហាត់បំណេះវិជ្ជា និងកិរិយាវត្តផ្សេងៗ ។

ង គ្រូអាចារ្យដែលចូលទៅបង្រៀនសិស្សក្នុងសាលា ត្រូវយកចិត្តទុកដាក់បំពេញកិច្ចរបស់សាលាឲ្យគ្រប់គ្រាន់ នឹងយកចិត្តទុកដាក់

បង្រៀនសិស្សឲ្យម៉ឺងម៉ាត់ កុំប្រកាន់មានះឫកពា ទាល់តែសិស្សលែងស្រឡាញ់អក្សរសាស្ត្ររបស់ជាតិខ្លួន ។

ប. បុរសស្ត្រីក្នុងគ្រួសារ ត្រូវយកចិត្តទុកដាក់ព្យាយាមបំពេញកិច្ចការសម្រាប់គ្រួសារ ប្រចាំត្រកូលឲ្យពេញលេញ កុំឈ្លួចតែរក្សាខ្លួនពេក ។

ផ. វុឌ្ឍបុគ្គល (បុរសស្ត្រីចាស់ៗ) ត្រូវសង្វាតខំប្រឹងឃ្នាតរៀនប្រដៅយុវជនឲ្យបានល្អត្រឹមត្រូវតាមគួរ កុំបណ្ដោយឲ្យខូចឫកពា និងសីលធម៌ដែលយើងគួររក្សាទុក ។

ព. ទាហានត្រូវប្រព្រឹត្តវិន័យ ប្រចាំបន្ទាយ ប្រចាំកង ប្រចាំជាតិ ហ៊ានត្រូវអង់អាចក្លាហានតស៊ូនឹងសត្រូវក្នុងពេលដែលប្រទេសត្រូវការពឹងខ្លួនយើងឲ្យជាអ្នកទទួលភារៈការពារ ។

ភ. អ្នកនិពន្ធ ត្រូវសរសេរសៀវភៅ ឬក៏និពន្ធតែងរឿងកំរផ្សេងៗ មានរឿងព្រះពុទ្ធសាសនា និងរឿងប្រវត្តិសាស្ត្រជាដើម ឲ្យបានសម្បូណ៌គ្រប់គ្រាន់ឡើង ។

ម. រដ្ឋបាល ត្រូវជួយឧបត្ថម្ភទំនុកបម្រុងកសិករ រក្សាផលប្រយោជន៍ និងសេចក្ដីសុខចំរើនរបស់កសិករ ឲ្យបានពេញលេញតាមលក្ខខណ្ឌៈការគ្រប់គ្រងដែនដី កុំឲ្យដែនដីបាក់ឡោសនៅថ្ងៃក្រោយ ។

ឆ. កក្តីប្រជា ត្រូវប្រកបការអាជីព តាមថ្នាក់ខ្លួនជាសាមញ្ញ កណ្តាលខ្ពស់ទាបតាមទម្ងន់កំលាំង ហើយបង់ពន្ធដារជូនរាជការតាមច្បាប់បវេណីរបស់ប្រទេស ។

ជ. គណៈសង្ឃគ្រប់ពុទ្ធសាសនា ត្រូវតាក់ការទំនុកបម្រុងព្រមទាំងទទួលការៈប្រកាសសាសនាតាមការបេះដូង ដើម្បីនឹងជួយលើកយោងប្រទេសឲ្យបានថ្កុំថ្កើងឡើងផង ។

ឈ. អ្នកប្រាជ្ញ ត្រូវតាក់ការលេងល្បែងឲ្យបានទាន់សម័យ កុំរវល់តែគួរអើយ ទាន់អើយ នឹងការលេងរឿងជណ្តើមបល្ល័ង្កនាគគ្រួយសោយរាជ្យក្រុងមួយយប់ៗ បួនដប់ជង ជាដែលៗពេក ត្រូវតាក់ការលេងទៅជាផ្លូវដឹកនាំជាតិឲ្យឡើងកាន់អារ្យប្រទេសបានវិញ កុំរវល់តែកសិប្រស់នឹងជប់មនុស្សស្លាប់ឲ្យរស់ឡើងវិញ នាំឲ្យអ្នកមើល អួតស្តាប់ក័ន្តតំនិក ។

ទោយប្រគ្រាន់ការដែលបានពោលមកខាងលើនេះ ជាផ្លូវដឹកនាំប្រទេសឲ្យដើរទៅកាន់អារ្យធម៌បានតាមបំណង ដោយកំឡាំងការយ៉ាងនេះ ហៅថា ការសាមគ្គី ។

២- របៀបសាមគ្គី ការព្រមព្រៀងគ្នា ដោយហេតុនោះគឺមនុស្សគ្រប់លោកទាំងមូលនេះមានច្រើនជាតិ ច្រើនសាសន៍ បើកប់តាមចំនួនក៏ឃើញថាច្រើនណាស់ ដូចជាជាតិខ្មែរ ចិន យួន សៀម លាវ ជាដើម ជាតិ

ទាំងអស់នេះ សុទ្ធតែមានសំដីភាសាផ្សេងៗ គ្នា ឲ្យមប្រើភាសារបស់ជាតិមិនឲ្យប្រែទៅ ប្រកាន់ជាតិ ប្រកាន់ភាសាតែរៀងខ្លួន លើកភាសារបស់ខ្លួនជាជាការៈឯកកល់ៗ ប្រទេសដែរ សូម្បីជាតិណាៗ ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ក៏ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យរៀនសូត្រអានបាលីតាមសំឡេងអក្សររបស់ជាតិកល់ៗ ជាតិដែរ ព្រោះទ្រង់ពិចារណាឃើញថា ជាការងាយស្រួលសិក្សា អាចឲ្យសម្រេចប្រយោជន៍បាន ។

ដោយហេតុនេះ បានជាអ្នកកាន់ព្រះពុទ្ធសាសនាកល់ប្រទេសសព្វថ្ងៃនេះ គេប្រកាន់វិធីអានបាលីក្នុងសូត្រផ្សេងល្អៀងពីគ្នាខ្លះដោយអក្សរ ៗ កម្រៃទៅតាមអក្ខរប្បវេទរបស់ខ្លួន ព្រោះគេកាន់ដល់ពុទ្ធានុញ្ញាត ក្នុងខុទ្ទកវត្ថុក្ខន្ធក វិន័យបិដក ចុល្លវគ្គ[1] ។

ជាតិណាតែគេស្រឡាញ់ជាតិភូមិរបស់គេហើយ គេក៏ស្រឡាញ់សំដីភាសា និងអក្សរសាស្ត្ររបស់គេដែរ គេយល់ថាសំដីភាសារបស់គេត្រឹមត្រូវល្អ ពិរោះ គាប់ចិត្ត បើទុកជាគេប្រជុំប្រឹក្សាពីកិច្ចការពារជាតិគេឲ្យមប្រើភាសារបស់ជាតិជាដរាប, ប៉ុន្តែភាសាឯទៀតៗ ក៏ត្រូវតែរៀនឲ្យចេះនឹងមានសោះក៏ពុំបាន ។ សូមទាញឧទាហរណ៍បង្ហាញឲ្យឃើញថា ដូចជាសន្ស្រេត, ហារ៉ាក, ទុកសព្វខ្លួនជាដើម គេតាប់

---

១ វិន័យបិដកចុល្លវគ្គភាគ ១១ បត្ត ២៩០ ទំព័រ ២៣០ និង ២៣១ ។

យកមកចិញ្ចឹមតាំងពីតូច ហើយគេបង្រៀនឲ្យនិយាយភាសាមនុស្ស
សត្វអស់នោះក៏ចេះនិយាយបានខ្លះដែរ, តែបើទុកជាដូច្នោះ ក៏គង់នៅ
តែមិនលះបង់សំនៀងភាសាសត្វ ។ ឧទាហរណ៍មកប៉ុណ្ណេះ
នេះឲ្យឃើញថា សូម្បីសត្វតិរច្ឆានដែលគេយកមកនៅអាស្រ័យនឹងមនុស្ស
យូរខែយូរឆ្នាំក៏ដោយក៏គង់នៅតែស្រឡាញ់ជាតិភាសាវាដដែល ។

យើងជាជាតិមនុស្សខ្ពស់ជាងសត្វតិរច្ឆាន បើមិនខិតខំប្រើភាសា
សំដីរបស់ជាតិឲ្យត្រឹមត្រូវ មិនស្រឡាញ់ភាសារបស់ជាតិទេ ឈ្មោះថា
មនុស្សអន់ជាងសត្វតិរច្ឆានទៅទៀត ។

ហេតុនេះ យើងត្រូវស្រឡាញ់ភាសាសំដីរបស់ជាតិឲ្យជាជាង
ភាសាឯទៀត, ហើយត្រូវពោលតែពាក្យពិត ពាក្យល្អ ពីរោះគាប់ចិត្ត
ពោលទៅហើយកើតផលប្រយោជន៍ ដែលអ្នកផងស្រឡាញ់ពេញចិត្ត,
កុំពោលពាក្យគ្រោតគ្រាតប្រទេចផ្ដាសា ពាក់ដោត រកគុន ញុះញង់
នាំអុជអាល បង្កាច់ បង្ខូច សង្កត់សង្កិន ញាំញី នាំឲ្យកើតក្ដៅក្រហាយ
ឲ្យបែកសាមគ្គី ឲ្យខូចផលប្រយោជន៍ជាតិ សាសនា និងព្រះមហា-
ក្សត្រឲ្យសោះ, បើយើងមិនកាន់ មិនប្រើប្រព្រឹត្តតាមបែបនេះទេ
សេចក្ដីវិនាសអន្តរាយ ក៏មុខជានឹងកើតមានប្រាកដ សេចក្ដីចំរើននឹង
មិនមានឡើយ ។

ការព្រមព្រៀងគ្នាដោយការពោលពាក្យសំដីយ៉ាងនេះ ហៅថា វចីសាមគ្គី ។

៣- មនោសាមគ្គី ព្រមព្រៀងគ្នាផ្លូវចិត្ត នោះ គឺ: មនុស្សយើងប្រុសស្រីដែលកើតមកក្នុងពិភពលោកនេះ មានចិត្តគំនិតអធ្យាស្រ័យខុសៗគ្នា ខ្លះចិត្តល្អ ខ្លះចិត្តអាក្រក់ រីឯគំនិតការអ្វីៗ ឬធ្វើការអ្វីៗ ក៏មិនដូចគ្នា ច្រើនតែតាមសុខៈ ឃ្លាងខ្លួនគំនិតគ្នា មិនស្របគ្នា គំនិតយ៉ាងនេះ រមែងមានជាធម្មតារបស់មនុស្សគ្រប់ជាតិ ។ អ្នកប្រាជ្ញទាំងឡាយ បានសង្កេតឃើញថា ក្នុងក្រុម គណៈ សង្គម ឬប្រទេសទីមួយៗ បើមានចិត្តគំនិតអធ្យាស្រ័យមិនព្រមព្រៀង មិនស្របគ្នាបែបនេះហើយ ក្រុម គណៈ សង្គម ឬ ប្រទេសនោះៗ មិនមានតម្លៃ មិនមានប្រយោជន៍ មិនលឿនទៅកាន់សេចក្ដីសុខ-ចំរើនបានទេ ច្រើនតែដល់នូវសេចក្ដីវិនាស ឬសេចក្ដីអាប់អោន ។

ប្រទេសទីមួយៗ លុះតែអាស្រ័យនូវសេចក្ដីព្រមព្រៀងគ្នាដោយចិត្ត គឺមានចិត្តគំនិតអធ្យាស្រ័យត្រូវគ្នា ស្របគ្នា មិនឃ្លាងខ្លួនគំនិតគ្នា ទោះបីធ្វើកិច្ចការ ឬគិតគូរ មិនលបលាក់ធ្វើ ឬគិតម្នាក់ឯង, មិនមានពុតត្បុតអាក្រក់ មិនក្បត់ចិត្តគ្នាឯង មិនមានគំនុំគុំគួនអាឃាតព្យាបាទគ្នាឯង ប្រាប់សេចក្ដីកំបាំងដល់គ្នាឯង មិនលាក់សេចក្ដីកំបាំងដល់គ្នាឯង ឲ្យគ្នាឯងបានសេចក្ដីសុខ-ចំរើន មិនឲ្យគ្នាឯងដល់នូវសេចក្ដីវិនាស ។

បើមានគំនិតអញ្ញមញ្ញស្រ័យព្រមព្រៀងគ្នា ដោយចិត្តបែបនេះហើយ ប្រទេសជាតិក្រុមគណៈ សង្គម សាសនា នឹងស្ទុះឡើងទៅកាន់សេចក្ដីចំរើនយ៉ាងឆាប់រហ័សពុំខាន, យ៉ាងនេះ ហៅថា មនោសាមគ្គី ។

ការព្រមព្រៀង មូលមិត្រស្រុះស្រួលគ្នា ដូចបានពោលមកខាងលើនេះ រាប់ថាជាគុណសម្បត្តិ ឬជាកំឡាំងមួយយ៉ាងវិសេសក្នុងលោក មានអានិសង្សអាចទាញអ្នកប្រតិបត្តិនោះ ឲ្យដើររហៀនទៅកាន់សេចក្ដីចំរើនគ្រប់កាលសម័យនិយម សត្រូវក៏ពុំហ៊ានបៀតបៀនឡើយ ។

សំដែងអំពីបរិយាយសាមគ្គី ចប់តែប៉ុណ្ណេះ ។

កាលបើចប់ធម្មទេសនាហើយ សូមផ្សាយចំណែកកុសលបុញ្ញរាសី ដល់អស់លោក អ្នកជាពុទ្ធបរិស័ទទាំងឡាយ នៅក្នុងកម្ពុជរដ្ឋទាំងមូល ឲ្យបានសេចក្ដីសុខ - ចំរើនគ្រប់ប្រការតរៀងទៅ ។

ទុក្ខរោគភយា វេរា សោកា សត្តុចុបទ្ទវា

អនេកា អន្តរាយាបិ វិនស្សន្តុ ច តេជសា

សេចក្ដីទុក្ខ នឹងរោគ នឹងភ័យ នឹងពៀរទាំងឡាយក្ដី សេចក្ដីសោក នឹងសត្រូវ នឹងឧបទ្រពទាំងឡាយក្ដី អន្តរាយទាំងឡាយដ៏ច្រើនក្ដី សូមឲ្យវិនាសបាត់ទៅដោយតេជះ ( នៃធម្មទេសនានេះ ) ។

បរិយាយសាមគ្គី ចប់

# ពាក្យប្រារព្ធ

រឿងពន្លឺអាស៊ីទ្វីបនេះ មានសេចក្ដីប្រែជាច្រើនជាតិច្រើនភាសា នៅទ្វីបអឺរ៉ុបនិងទ្វីបអាស៊ី រហូតដល់ទៅទ្វីបអាមេរិក ដូចមានបរិយាយអំពីរឿងនេះនៅក្នុងការម្ភកថា របស់អ្នកប្រែជាភាសាបារាំងសែសស្រាប់ ។ ឯសេចក្ដីប្រែជាខេមរភាសានេះ យើងបានអាស្រ័យសេចក្ដីប្រែជាភាសាបារាំងនិងសេចក្ដីប្រែជាភាសាថៃ សម្រួលពាក្យពេចន៍ឲ្យបានងាយយល់ងាយស្ដាប់ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនជាតិយើង ។

ត្រង់ឈ្មោះរឿងក្នុងសៀវភៅជាភាសាបារាំងសែស ហៅថា "ឡាលុយមីញែរ ដឺអាស៊ី" (La Lumière de l'Asis) ឈ្មោះសៀវភៅរបស់រឿងដដែលនេះ ជាភាសាថៃ ហៅថា "ប្រទីបនៃទ្វីបអាស៊ី" ។ ឯឈ្មោះរឿងក្នុងសៀវភៅជាខេមរភាសាយើងនេះ ហៅថា "ពន្លឺអាស៊ីទ្វីប" ។ ដោយហេតុសេចក្ដីក្នុងរឿងរបស់សៀវភៅនេះ មានសេចក្ដីពិរោះពិសារដោយអត្ថរសនិងពាក្យពេចន៍ បានជាត្រូវគេប្រែតៗគ្នាចេញទៅជាច្រើនភាសា ហើយក្នុងភាសានិមួយៗ គេបានបោះពុម្ពផ្សាយចេញជាច្រើនលើកច្រើនគ្រា ដរាបតាមសេចក្ដីត្រូវការរបស់ប្រជាជនក្នុងប្រទេសនោះៗ ។ ឯសេចក្ដីប្រែជាខេមរភាសាយើងនេះ យើងមិនគាប់ជាអាចប៉ាន់ថា មានសេចក្ដីពិរោះពិសារជាង ឬប្រហែលនឹងសេចក្ដី

ប្រែជាភាសានានាប្រទេសនោះទេ ប៉ុន្តែយើងយល់ថាគម្ពីរស៊ូត្របនេះ ថ្លែងពីប្រវត្តិ ព្រះធម្មចរិយា និងព្រះបញ្ញត្តិជាដើម របស់ព្រះសម្មា-សម្ពុទ្ធជាម្ចាស់ប៉ែកខាងមហាយាន ដែលមានសេចក្ដីដើមជាភាសាសំស្ក្រឹត សឹងមានសេចក្ដីថ្លៃរឿងស្របគ្នាខ្លះ ខុសគ្នាខ្លះដោយអន្លើ ៗ នឹងពុទ្ធប្រវត្តិប៉ែកខាងហីនយានរបស់យើង ។

ហេតុដូច្នេះ ទើបគួរតែពុទ្ធសាសនិកជនជាតិយើង ដែលគោរពលទ្ធិថេរវាទឬហីនយាន គប្បីសិក្សាពុទ្ធប្រវត្តិ និងគោលធម៌អាថ៌សំខាន់ៗ ព្រមទាំងរឿងរ៉ាវផ្សេង ៗ ប៉ែកខាងមហាយានឲ្យបានបេះជើងឡើងខ្លះ ជាគ្រឿងប្រដាប់សតិបញ្ញារបស់យើង ។ នៅទីបំផុត យើងអាចយល់ឃើញជឿជាក់ថា គ្រាន់តែអានម្ដងៗ របស់អ្នកប្រាជ្ញភាសាបារាំងសែស ឬភាសាអង់គ្លេស ក៏ល្មមជាគ្រឿងបញ្ចេញពន្លឺរស្មីនៃព្រះពុទ្ធសាសនា ឲ្យឃើញច្បាស់ថា គុណធម៌របស់ព្រះពុទ្ធសាសនាបានសាយភាយចេញទៅ ស្ទើរតែសព្វពិភពផែនដី ។ មនុស្សលោកសំដែងសេចក្ដីគោរពចំពោះព្រះពុទ្ធសាសនា មានចំនួនអស់ទៅ ១ ក្នុងភាគ ៣ គួរឲ្យអស្ចារ្យដល់អានុភាពនៃព្រះពុទ្ធសាសនាពន់ពេកណាស់ ។

ហួងមិតទូមទ្រី ញ៉ុក - ថែម

បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

# ពន្លឺអាស៊ីទ្វីប

## កថាមុខរបស់អ្នកប្រែ

(ពីភាសាអង់គ្លេស ជាភាសាបារាំងសែស)

---

ពាក្យកាព្យដែលមានសេចក្ដីដោយសង្ខេបនេះ មានរសជាតិពីរោះ ចាប់ចិត្ត, ពោលអំពីរឿងកំរដ៏អស្ចារ្យ, ថ្លែងអំពីលទ្ធិវិសេសរបស់ព្រះពុទ្ធ រឿងនេះបានខ្ចាត់ខ្ចាយសាយភាយចេញទៅក្នុងចំណោមប្រទេសអង់គ្លោសាក់ស៊ុង (Anglo saxons) ហើយមានកើតសៀវភៅជាច្រើនដែលអ្នកប្រាជ្ញបានសរសេរឡើងអំពីរឿងដដែលនេះ; នៅក្រុងឡុង (ប្រទេសអង់គ្លេស) គេបានបោះពុម្ពផ្សាយមកហើយដល់ ៩០ លើក នៅប្រទេសសហរដ្ឋអាមេរិក គេបានបោះពុម្ពដល់ទៅជាង ១០០ លើកមកហើយ; មួយវិញទៀត គេបានប្រែចេញជាភាសាអឺរ៉ុបនិងភាសាខាងបូព៌ាប្រទេស ជាច្រើនភាសា, នៅប្រទេសឥណ្ឌា គេបានប្រែជាបែបសិក្សាផង ។

យើងបានយល់ឃើញថា គួរតែបកផ្សាយរឿងដ៏មានខ្លឹមសារនេះ ដែលជាស្នាដៃរបស់កវីជាន់ឯកម្នាក់ នៃប្រទេសអង់គ្លេស ក្នុងសម័យបច្ចុប្បន្ននេះ ឲ្យបានដឹងឮពេញគ្នាឡើង ក្នុងប្រទេសបារាំងសែសនេះ ដើម្បីសេចក្ដីនៃរឿងដាក់សៀវភៅ «ពន្លឺអាស៊ីទ្វីប» នេះ ដែលជារឿងថ្លែងអំពីយោបល់ដ៏ខ្ពង់ខ្ពស់ របស់ប្រទេសទិសខាងលិច ពីព្រោះ

បើតាមការសង្កេតដ៏ទៀងទាត់របស់លោក ស៊ីវ្រយ៉ុង នោះយល់ឃើញថា "របស់ដែលពួកមហាបុរសកំពូនទាំងឡាយសិក្សាក្នុងសម័យបច្ចុប្បន្ននេះ ពួកមុនីពុទ្ធសាសនាបានបង្ហាត់បង្រៀន តាំងអំពី ២៣ សតវត្សរ៍មកហើយ" ។

ការពិចារណាឲ្យឃើញទុក្ខ និងការតស៊ូរបស់ពិភពលោក បញ្ញត្តិនៃការប្រែប្រួល បច្ច័យាការ ដំណើរទៅ ៗ គ្មានឈប់ឈរ, ការផ្តុំរូបរួមគ្នានៃលោក អាការជាប់ជំពាក់ទាក់ទងយ៉ាងជិតស្និទ្ធនៃសត្វលោក ការប្រែប្រួលជាភាពផ្សេង ៗ មិនទៀងទេ ការបន្ថយអំពើអាក្រក់ឲ្យតិចចុះទៅ ដោយការបន្ថែមចំណេះចេះដឹងឲ្យចំរើនកើនឡើង ការបំពេញប្រយោជន៍អ្នកដទៃ និងការសាមគ្គីរួបរួមគ្នា ទិដ្ឋិយោបល់ទាំងនេះសុទ្ធតែត្រូវតាមវិទ្យាសាស្ត្រ និងប្រាជ្ញាវិទ្យាទំនើបថ្មី នេះហើយដែលជាសេចក្តីពិតដ៏ខ្ពង់ខ្ពស់ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាទុកមក ។

កាលទ្រង់ជ្រួតជ្រាបយ៉ាងជាក់ច្បាស់ ដោយទ្រង់ទតឃើញទុក្ខសោក និងការវឹកវររបស់សព្វសត្វដែលមានជីវិតទាំងពួង ទើបទ្រង់តាំងព្រះទ័យដាច់ស្រេចថា នឹងស្វែងរកមូលហេតុនិងថ្នាំសំរាប់បំបាត់រោគនេះ ។ ហេតុដូច្នេះហើយ បានជាព្រះអង្គទ្រង់លះបង់សេចក្តីសុខសម្រាន្តដែលទ្រង់បានសេពសោយ ស្តេចយាងចេញទៅគង់នៅតែមួយព្រះអង្គឯង

ហ្វាតធ្លាយពាកការកើតកើតរែកកាយ ទីដ៏កាតតណ្ហា ដែលធ្វើឲ្យព្រះទ័យខ្វក់ខ្វល់ ហើយទ្រង់បានចំឡើងព្រះហឫទ័យឲ្យធ្វើផុតចាកគំនិតចាស់ទាំងអម្បាលមាន ដោយទ្រង់ផ្ចង់ព្រះហឫទ័យក្នុងផ្លូវសមាធិការនា ។

មុនដំបូង ព្រះអង្គទ្រង់បានជ្រាបច្បាស់ថា ព្រះអង្គមិនអាចរកឲ្យឃើញផលសម្រេចនៃប្រាថ្នានេះទេ ទោះបីនៅស្ថានសួគ៌ក្តី ទោះបីនៅស្ថានមនុស្សលោកដែលឥតឋិតថេរនេះក្តី ប៉ុន្តែនៅមានការពិតតែមួយ ដែលយើងរេះដឹងយល់បានក្លាយ គឺសេចក្តីពិតដែលនៅក្នុងខ្លួនយើងនេះ ហើយជាថ្នាក់ដំបូង ដែលត្រូវអាស្រ័យការពិចារណា, កិច្ចការមើលសេចក្តីប្រព្រឹត្តរបស់យើង ហើយទ្រង់បានពិនិត្យពិចារណាវិធីប្រតិបត្តិ ទ្រង់ក៏បានជួបប្រទះនឹងហេតុផលដែលគ្មានអ្នកណាកែខៃទៀតបាន ទាំងទៀនទាត់ជានិច្ចនិរន្តរ៍ ដែលព្រះអង្គទ្រង់ប្រមូលបញ្ចូលនៅក្នុងមហាបញ្ញត្តិរបស់កម្ម ។

ព្រះអង្គទ្រង់យល់ឃើញថា កម្មរបស់យើងតែងបង្កើតខ្លួនឯង កម្មនោះរេះតែបង្កើនឡើងៗ គ្មានឈប់ជាប់នៅ ចំរើនខ្លាំងក្លាឡើងដោយការខ្ជាប់ ពាក់ពន្ធឡើងនៅក្នុងខ្លួនយើង នៃប្រសន្នចិត្តរបស់យើង, លក្ខណៈរបស់យើង មិនឲ្យដឹងខ្លួន ទោះបីកន្លងកាយក៏ត្រូវតែប្រែជារ ដោយហេតុនេះ កម្មល្អតែងឲ្យផលល្អដល់យើង កម្មអាក្រក់តែងធ្វើឲ្យយើងបានទុក្ខទោស ហើយសៅសោកក្រៀមក្រំ

គឺយើងត្រូវតែបានទទួល ផ្ទាន់ ៗ ផលនៃការងាររបស់យើងដោយខ្លួនឯង មួយវិញទៀត ព្រះអង្គទ្រង់យល់ឃើញថាផលនៃសេចក្តីប្រព្រឹត្តទាំងនេះ តែងតែកើតបដិកិរិយា ជាអានក្រោយការរស់នៅឥតខ្ជាប់ខ្លួន តាមចំណង នៃខ្សែស្រឡាយទាំងឡាយរកទីបំផុតនានគឺជាកូនចៅរបស់យើងបណ្តោះ បណ្តាលឲ្យបានផលចំរើនឡើង ឬបានទទួលទុក្ខវេទនាវៀរលែងសាប សូន្យទៅ, សូម្បីខ្លួនយើងសោតទៀត ដែលបានសប្បាយ ឬ ទុក្ខសោក ក៏សុទ្ធតែជាផលដែលជាមត៌ករបស់ខ្លួនឯង អំពីអតីតកាល ។

នៅក្នុងវដ្តនៃការពិនិត្យពិចារណារបស់ព្រះអង្គ ព្រះពុទ្ធជាម្ចាស់ ទ្រង់យល់ថា លោកនេះជាទីស្នាក់បណ្តោះអាសន្នរបស់សត្វលោកកើត ឡើងជារូបភាពផ្សេង ៗ ទាំងពាន់ចាំង ចងភ្ជាប់ជាមួយគ្នានឹង "កង់" នៃការវិលប្រែប្រួលទៅ ដោយកម្លាំងប្រឹងប្រែងរបស់ខ្លួនឯង ។

នៅទីបំផុត យើងរាល់គ្នា នៅក្នុងកំរិតជាប់ស្រេច, រួបរួមនៅក្នុង ជាគជគាមួយជាមួយគ្នា ឥតឥស្សរភាព ចងបាច់គ្នាយ៉ាងម៉ឺងម៉ាត់ យើងត្រូវរួបរួមកិច្ចការជាមួយគ្នា ទោះឥតចេតនាឬមានចេតនាក៏ដោយ តែដែលនាំឲ្យយើងបានទទួលសេចក្តីសុខរបស់ខ្លួនឯងបាននោះ លុះតែ យើងជួយអ្នកឯទៀតឲ្យបានសេចក្តីសុខដែរ ផលបដល់បានសម្រេចសេចក្តី

សុខដ៏ខ្ពង់ខ្ពស់ផុត គឺព្រះនិព្វាន:(១) ព្រមទាំងជីកឲ្យដើរតាមដំណើររបស់យើង ដោយការមិនទីកនាដល់ប្រយោជន៍ផ្ទាល់ខ្លួន, គឺការមេត្តាប្រណីនឹងការធ្វើទាន ។ បើពោលដោយផ្ទុយគ្នានោះ សេចក្តីទុក្ខជាហេតុបង្កើតអវិជ្ជា ដែលជាគួលក្រឹមបញ្ញាតយើងឲ្យយល់ខុសជាត្រូវ, នាំឲ្យយើងមានមច្ឆរិយៈ, លោភទ្រព្យសម្បត្តិដែលមិនប្រើតថេរ ហើយនាំឲ្យដើរខុសតាម "ផ្លូវទៀងត្រង់" ។ ផ្ទុយពុះ ទើបឃើញច្បាស់ថាមានតែវិជ្ជានឹងការមេត្រី, បរមត្ថធម៌នឹងសីលធម៌ទេ ដែលជាគ្រឿងកំចាត់រំលាយបញ្ហានៃសេចក្តីទុក្ខ លើកលែងការគស្ហីតានឹងការព្រយល់បាត ព្រមទាំងញ៉ាំងបរមត្ថសុខផ្ទាល់ខ្លួន នឹងសម្រាប់លោកឲ្យកើតឡើងបានផង ។ (មានត)

• យើងយល់សមតាមលោក អិតវិន អារណុល់ត៍ (M. Edvin Arnold) ក្នុងសេចក្តីដែលថា ព្រះនិព្វាននោះមិនមែនជាធម្មជាតិរលត់សូន្យឈឹងទេ ទាំងមិនមែនជាសភាពទ្រទ្រង់នៅជាប់ស្រាប់ យើងមិនត្រូវការរកបន្ទាល់សាក្សីដទៃទៀត ក្រៅពីព្រះពុទ្ធភាសិតថា កាលបើបានជួយខ្លួនឯងរួចហើយ ត្រូវជួយអ្នកដទៃទៀតផង, កាលខ្លួនបានឆ្លងដល់ត្រើយឯណាហើយ ត្រូវជួយចម្លងអ្នកដទៃឲ្យបានឆ្លងដល់ត្រើយនោះផង, ចូរដោះទុក្ខខ្លួនដើម្បីដោះទុក្ខរបស់គេផង, កាលខ្លួនបានលុះដល់ព្រះនិព្វានជាប់ស្រេចហើយ, ត្រូវជួយអ្នកដទៃឲ្យបានលុះដល់ព្រះនិព្វាននោះផង; និព្វាន គឺធម្មជាតិដែលមាននៅឋានទីបំផុត ហើយទៀងទាត់ជានិច្ច ។ តាមដោយពិតនោះ មានអ្នកបេះត្រិះរិះដ៏ប្រសើរម្នាក់ បានថ្លែងកំនិតយោបល់ដ៏ប្រសើរទុកថា "ការរស់នៅរួមជាមួយនឹងអ្នកដទៃ ជាជីវិតដ៏ខ្ពង់ខ្ពស់ ព្រោះតែកាលណាយើងបានឆ្លងត្រើទេត្តរបស់យើង ដោយគុណសេរីភាពហើយ យើងមុខជាលែងជួបប្រទះនឹងពិប្រទល់ផ្លូវប្រោះទៀត ហើយទ្វារនៃសភាវៈ ឋានទីបំផុត (និព្វាន) ក៏នឹងបើកចំហសម្រាប់យើង" Y. Georès Revue de Reine 1er Décembre 195[illegible]

# អំពីការតាំងចៅអធិការថ្មី

ចាប់តាំងពីខែមករា ឆ្នាំ១៩៤៣ - ៤៨

សញ្ញាប័ត្រលេខ ១ ចុះថ្ងៃពុធ ២ កើត ខែបុស្ស ឆ្នាំច អដ្ឋស័ក តាំងលោកភិក្ខុ អាន-មៅ នាមឆាយា ធម្មសុវណ្ណ កើតឆ្នាំមមី អាយុ ៥២ វស្សា ៣១ ជាចៅអធិការវត្តឥន្ទ្រវិលារាម ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២ ចុះថ្ងៃព្រហស្បតិ៍ ១០ កើត ខែបុស្ស ឆ្នាំច អដ្ឋស័ក តាំងលោកភិក្ខុ អ៊ុម-យី នាមឆាយា វិបុលបញ្ញោ កើតឆ្នាំជូត អាយុ ៣៤ វស្សា ១៤ ជាចៅអធិការ វត្តសុវណ្ណសខារាម ឃុំតាំងក្រសាំង ស្រុកទឹកផុស កំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៣ តាំងលោកភិក្ខុ ខាន ខុត នាមឆាយា ចន្ទសិរិ កើតឆ្នាំ ១៩០៨ អាយុ ៣៨ វស្សា ១៤ ជាចៅអធិការ វត្តព្រែជ ឃុំចង់ក្រែ ស្រុកល្វាឯម ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ៤ ចុះថ្ងៃ អង្គារ ១៥ កើត ខែ បុស្ស ឆ្នាំ ច អដ្ឋស័ក តាំងព្រះញាណកោសល នាមឆាយា ជោតិបញ្ញោ កើតឆ្នាំថោះ អាយុ ៥៥ វស្សា ៣៤ ជាចៅអធិការវត្តចម្ប៉ា ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ១ ចុះថ្ងៃ ២៩ មករា-៤៧ តាំងលោកភិក្ខុ គង់-ម៉ាន់ នាមឆាយា ធម្មការោ កើតឆ្នាំជូត អាយុ ៥៩ វស្សា ១៩ ជាចៅអធិការ វត្តសុវណ្ណារាម ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល (ប៉ែកខាងគណធម្មយុត្តិ) ។

សញ្ញាប័ត្រលេខ ២ ចុះថ្ងៃ ៣០ មករា-៤៧ តាំងលោកភិក្ខុ អ៊ុក-ទ នាមឆាយា ឥគ្គោ កើតឆ្នាំកុរ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការ វត្តសន្ទុង ឃុំសន្ទុង ស្រុកត្រាំង ខេត្តតាកែវ (ប៉ែកខាងគណធម្មយុត្តិ) ។

សញ្ញាប័ត្រលេខ ៦ ចុះថ្ងៃព្រហស្បតិ៍ ៨ រោច ខែមាឃ ឆ្នាំច អដ្ឋស័ក តាំងលោកភិក្ខុ គាត-តិច នាមឆាយា ធម្មបញ្ញោ អាយុ ៣៩ វស្សា ១៩ ជាចៅអធិការវត្តកោះអណ្ដែត ឃុំព្នាក់ ស្រុកក្ដុំពេញ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ១១ ចុះថ្ងៃចន្ទ ៥ កើត ខែផល្គុន ឆ្នាំចអដ្ឋស័ក តាំងលោកភិក្ខុ តា-ឌួន នាមឆាយា មន្ទុត្តរតី អាយុ ៦២ វស្សា ៤១ ជាចៅ-អធិការ វត្តក្បាកមាសលើ ឃុំព្រៃគ្រី ស្រុកកំពង់លែង កំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ១២ ចុះថ្ងៃ អង្គារ ៤ រោចខែផល្គុន ឆ្នាំចអដ្ឋស័ក តាំងលោកភិក្ខុ សាន់-ស៊ិន នាមឆាយា ព្រហ្មជោត កើតឆ្នាំរកា អាយុ ៤៧ វស្សា ២៦ ជាចៅអធិការវត្តក្បាន ឃុំតាសួច ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៣ ចុះថ្ងៃអង្គារ ៥ រោចខែផល្គុន ឆ្នាំចអដ្ឋស័ក តាំងលោកគ្រូ អ៊ុម-ផុន នាមឆាយា វិជ្ជជោត កើតឆ្នាំរកា អាយុ ២៥ វស្សា ៥ ជាចៅអធិការ វត្តឈូកស ឃុំព្រះស្រែ ស្រុកឧដុង្គ ខែត្រកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ១៥ ចុះថ្ងៃអង្គារ ៣ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ សម-ហម នាមឆាយា ចន្ទបញ្ញា កើតឆ្នាំមមែ អាយុ ៤១ វស្សា ១៧ ជាចៅអធិការ វត្តព្រះម្លូ ឃុំព្រះម្លូ ស្រុកបាកាន ខែត្រពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៦ ចុះថ្ងៃអង្គារ ៣ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ ស៊ូ-ចន្ទ នាមឆាយា ឥន្ទលិខិត កើតឆ្នាំជូត អាយុ ៤៨ វស្សា ២៧ ជាចៅអធិការ វត្តជ្រៃ ឃុំព្រះម្លូ ស្រុកបាកាន ខែត្រពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៧ ចុះថ្ងៃអង្គារ ៣ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ អ៊ុម-អៀម នាមឆាយា សុវណ្ណកេត្ត កើតឆ្នាំកុរ អាយុ ៣៦ វស្សា ១៦ ជាចៅអធិការ វត្តឧទ័មង្គលារាម ស្រុកបាកាន ខែត្រពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ១៨ ចុះថ្ងៃអង្គារ ៣ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ អ៊ូក-ប៊ុត នាមឆាយា ឥន្ទសុវណ្ណ កើតឆ្នាំរោង

អាយុ ៣២ វស្សា ១០ ជាចៅអធិការ វត្តទួលលៀប ស្រុកបាកាន ខេត្ត ពោធិសាត់ ។

សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃចន្ទ ២ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ ឧទុម-លាំង នាមធាយា ឥន្ទសុវណ្ណ អាយុ ៥០ វស្សា ៣០ ជាចៅអធិការវត្តអង្គស្តុក ឃុំឪឡោក ស្រុកក្ដំពេញ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ២០ ចុះថ្ងៃចន្ទ ២ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ អ៊ឹង-សុខ នាមធាយា មុនីជោតោ កើតឆ្នាំច អាយុ ៤០ វស្សា ១៧ ជាចៅអធិការវត្តគោក ឃុំលំហាច ស្រុកក្ដំពេញ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ២១ ចុះថ្ងៃចន្ទ ២ កើត ខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ ស៊ិង-ប៉ុប នាមធាយា ឥន្ទគេត កើតឆ្នាំមមែ អាយុ ៤០ វស្សា ២០ ជាចៅអធិការ វត្តឈូកធណ្ដុំ ឃុំទួលព្រេច ស្រុកក្ដំពេញ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ២២ ចុះថ្ងៃព្រហស្បតិ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ ទេព-រស់ នាមធាយា ឥន្ទតេសរ កើតឆ្នាំរោង អាយុ ៥៥ វស្សា ៣២ ជាចៅអធិការវត្តអង្គរោង ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៣ ចុះថ្ងៃព្រហស្បតិ៍ ៤ កើតខែពិសាខ ឆ្នាំកុរឯកស័ក តាំងលោកគ្រូ សោម កេត នាមធាយា ធម្មទេសរ កើតឆ្នាំមមែ អាយុ ៥២ វស្សា ៣២ ជាចៅអធិការ វត្តមន្ទីរមានជ័យ ឃុំពោធិ៍ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៤ ចុះថ្ងៃព្រហស្បតិ៍ ៤ កើតខែពិសាខ ឆ្នាំកុរឯកស័ក តាំងលោកគ្រូ សុខ-ស៊ុន នាមធាយា សុវណ្ណគេរ កើតឆ្នាំរក អាយុ ៣៦ វស្សា ១៦ ជាចៅអធិការ វត្តទួលទទាប ឃុំស្វាយរំពា ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៥ ចុះថ្ងៃព្រហស្បតិ៍ ៤ កើតខែពិសាខ ឆ្នាំកុរឯកស័ក តាំងលោកគ្រូ ស្រួស-អ៊ុប នាមធាយា ឥន្ទបញ្ញោ កើតឆ្នាំកុរ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការវត្តអង្គលំចង់ ឃុំស្នំក្រពើ ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៦ ចុះថ្ងៃព្រហស្បតិ៍ ៤ កើតខែពិសាខ ឆ្នាំកុរឯកស័ក តាំងលោកគ្រូ ប៉ប់-សួន នាមធាយា សុវណ្ណគេរ កើតឆ្នាំម្សាញ់ អាយុ ៦៤ ឆ្នាំ វស្សា ៤៤ ជាចៅអធិការវត្តបសែក ឃុំបសែក ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៧ ចុះថ្ងៃព្រហស្បតិ៍ ៤ កើតខែពិសាខ ឆ្នាំកុរឯកស័ក តាំងលោកគ្រូ វ៉ែន-ជា នាមធាយា ធម្មជោតគេរ កើតឆ្នាំជូត

អាយុ ៨៨ ឆ្នាំ វស្សា ៣៨ ជាចៅអធិការវត្តទួលគ្រាច ឃុំអង្គពពេល ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៨ ចុះថ្ងៃព្រហស្បតិ៍ ៨ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ ម៉ុក-ហ៊ូ នាមងាយា ចន្ទទត្តោ អាយុ ៨៥ ឆ្នាំ វស្សា ២៩ ជាចៅអធិការវត្តដីកជ្រៃ ឃុំទឹកល្អក់ ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៩ ចុះថ្ងៃព្រហស្បតិ៍ ៨ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ អ៊ូ-ម៉ាង នាមងាយា សុវណ្ណសរ កើតឆ្នាំរកា អាយុ ២៥ ឆ្នាំ វស្សា ៥ ជាចៅអធិការវត្តព្រះខែ ឃុំស្វាយបច្ចិម ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣០ ចុះថ្ងៃព្រហស្បតិ៍ ៨ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ សួស-អ៊ិម នាមងាយា ឥន្ទត្ថេរ កើតឆ្នាំមមី អាយុ ៦៥ ឆ្នាំ វស្សា ៩ ជាចៅអធិការវត្តអង្គអណ្ដែត ឃុំពោធិ៍អង្ក្រង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣១ ចុះថ្ងៃព្រហស្បតិ៍ ៨ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ សោម-កោះ នាមងាយា សុវណ្ណជោតត្ថេរ កើតឆ្នាំរោង អាយុ ៦៧ ឆ្នាំ វស្សា ៤៦ ជាចៅអធិការវត្តត្រពាំងធំ ឃុំពោធិ៍អង្ក្រង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣២ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ នព្វស័ក តាំងលោកគ្រូ សួស-ចាប នាមឆាយា ឧទ្ទុត្តោ កើតឆ្នាំរោង អាយុ ៦៧ ឆ្នាំ វស្សា ៤៦ ជាចៅអធិការវត្តអង្គពពេល ឃុំពោធិ៍អង្រ្កង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៣ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ នព្វស័ក តាំងលោកគ្រូ ម៉ែន-ប៊ូ នាមឆាយា ធម្មបញ្ញោ កើតឆ្នាំរោង អាយុ ៤២ ឆ្នាំ វស្សា ១៩ ជាចៅអធិការ វត្តអង្គមានជ័យ ឃុំរាល ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៤ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរ នព្វស័ក តាំងលោកគ្រូ ឯម-ខ្យាង នាមឆាយា ឯកត្ថោ កើតឆ្នាំកុរ អាយុ ៤៧ វស្សា ២៧ ជាចៅអធិការ វត្តព្រះពាន់ ឃុំរាល ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៥ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំឆ្លូវ អដ្ឋស័ក តាំងភិក្ខុ ម៉ែន:ញាណ នាមឆាយា មង្គលកេសរ កើតឆ្នាំកុរ អាយុ ២៤ វស្សា ៤ ជាចៅអធិការវត្តជ្រហូតៅ ឃុំរាល ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៦ ចុះថ្ងៃព្រហស្បតិ៍ ៥ កើតខែពិសាខ ឆ្នាំកុរនព្វស័ក តាំងលោកគ្រូ តង់-សុខ នាមឆាយា សុទ្ធត្តោ កើតឆ្នាំរោ

អាយុ ៤៩ ឆ្នាំ វស្សា ២៦ ជាចៅអធិការ វត្តសែនចៀវ ឃុំស្រែង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៧ ចុះថ្ងៃព្រហស្បតិ៍ ៩ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ ឯក លឹម នាមងាយា ឥន្ទជោតោ កើតឆ្នាំមមែ អាយុ ៥១ ឆ្នាំ វស្សា ៣១ ជាចៅអធិការវត្តតាកែម ឃុំស្រែង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៨ ចុះថ្ងៃព្រហស្បតិ៍ ៩ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ សោម-ប៊ិន នាមងាយា សុវណ្ណោ កើតឆ្នាំថោះ អាយុ ៤៣ ឆ្នាំ វស្សា ២៣ ជាចៅអធិការវត្តអង្គស្វាយ ឃុំស្រែង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៣៩ ចុះថ្ងៃព្រហស្បតិ៍ ៩ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ កែវ-ស៊ុម នាមងាយា សុវណ្ណោ កើតឆ្នាំច អាយុ ៣៩ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តកាត់ក្តុល ឃុំផុង ស្រុកគងពិសី កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៤០ ចុះថ្ងៃព្រហស្បតិ៍ ៩ កើតខែពិសាខ ឆ្នាំកុរ ឯកស័ក តាំងលោកគ្រូ គឹម គិក នាមងាយា ចន្ទជោតោ កើតឆ្នាំច អាយុ ២៦ ឆ្នាំ វស្សា ៤ ជាចៅអធិការវត្តកុល ឃុំផុង ស្រុកគងពិសី កំពង់ស្ពឺ ។

(មានត)

# សេចក្ដីជូនដំណឹង អំពីពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ ជាមន្ទីរសិក្សានិងការបោះពុម្ពផ្សាយខាងវិជ្ជាខ្មែរ អានទាំងបាលី-វិស្ដ្រិត ទាំងខាងផ្នែកគតិលោក ទាំងផ្នែកគតិធម៌ ។

ចុះបើសព្វថ្ងៃនេះ ការបោះពុម្ពផ្សាយលំបាកពន់ពេក ដោយហេតុខ្វះប្រដាប់ប្រដាសម្រាប់វេគពុម្ព ៗ មិនអាចបោះពុម្ពរឿងផ្សេងៗ ឲ្យបានរួសរាន់ទាន់កាលសម័យ ។ ពុទ្ធសាសនបណ្ឌិត្យ ក៏នៅតែខំប្រឹងលៃលកបោះពុម្ពសៀវភៅចាស់ៗ ខ្លះ ដែលចំណាយអស់ទៅ និងរឿងថ្មីៗ ខ្លះ ក្នុងឆ្នាំ ១៩៤៨ នេះ ។

## រឿងថ្មី

ទីកសម្រាយ: មហាវេស្សន្តរជាតក . . . . . . . . . . តំលៃ ១ ក្បាល ១៦រ, ០០

ទីកបាលី: កង្ខាវិតរណី (អដ្ឋកថាបាតិមោក្ខ) (គន្ថមាលា សម្រាប់សាលាបាលីជាន់ខ្ពស់ កំពុងបោះពុម្ព)

## រឿងដែលបានបោះពុម្ពឡើងវិញ

១— សត្តបរិត្ត - ទ្វាទសបរិត្ត . . . . . . . . . . . . . . តំលៃ ១ ក្បាល ១៤រ, ០០

២— សាមណេរវិន័យ . . . . . . . . . . . . . . . . — ៥, ៥០

៣— អនុមោទនាវិធី . . . . . . . . . . . . . . . . — ៦, ៥០

៤— នានាជាតក . . . . . . . . . . . . . . . . — ១២, ០០

៥— គិហិបដិបត្តិ . . . . . . . . . . . . . . . . —

## (ចាំរង់បោះពុម្ពតទៅទៀត)

៦— កច្ចាយនូបត្ថម្ភ

៧— ធម្មបទភាគខ្លះ ដែលខ្វះខាត

៨— ភាណវារៈបាលី

៩— សត្តន្ធមាលា

០— វិន័យបាតិមោក្ខ

១— មង្គលត្ថទីបនី ភាគខ្លះដែលខ្វះខាត

២— វិសុទ្ធិមគ្គ ភាគខ្លះដែលខ្វះខាត

សូមអស់លោកដែលត្រូវការសៀវភៅទាំងប៉ុន្មានមុខខាងលើនេះ ចូលទៅរកទិញបាន [illegible]